# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2012, 08:08
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## បណ្តឹងសាទុក្ខរបស់លោកអៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់លោក អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវីការពារក្តី៖**

លោក **អាង ឧត្តម**

លោក Michael G. KARNAVAS

**<u>ដាក់ជូន ៖</u>**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម **គង់ ស្រីម** ជាប្រធាន

ចៅក្រម **សោម សិរីវឌ្ឍ**

ចៅក្រម **ម៉ុង មុនីចរិយា**

ចៅក្រម **យ៉ា ណារិន**

ចៅក្រម MOTOO Noguchi

---

ចៅក្រម **Agniezska KLONOWIECKA-MILART**

ចៅក្រម **Chandra Nihal JAYASINGHE**

ចៅក្រមបម្រុង **ស៊ិន រិទ្ធ**

ចៅក្រមបម្រុង **Florence MUMBA**

**សហព្រះរាជអាជ្ញា**

លោកស្រី **ជា លាង**

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

អនុលោមតាមវិធាន ១០៤ និងវិធាន ២១ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធានផ្ទៃក្នុង") លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("ក្រុមមេធាវីការពារក្ដី")[១] សូមដាក់បណ្ដឹងសាទុក្ខជំទាស់ទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សំណើរបស់លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ (ឯកសារលេខ E154) [សំណើ]" ("សេចក្ដីសម្រេចដែលត្រូវបានជំទាស់")[២]។ វាជាការចាំបាច់ក្នុងការដាក់បណ្ដឹងសាទុក្ខនេះ ដោយសារលោកស្រី Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង តាមការបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង បានធ្វើការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង* (*ex parte*) ជាមួយភាគីមួយចំនួនពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ។ ក្រុមមេធាវីការពារក្ដីបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនបញ្ឈប់ការប្រព្រឹត្តមិនសមស្របរបស់គាត់ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបង្គាប់មិនឱ្យភាគីឆ្លើយតបទៅនឹងសំណើនេះ ហើយបានច្រានចោលសំណើនេះភ្លាមៗ តាមរយៈអនុស្សរណៈដែលមិនមានសំអាងហេតុគ្រប់គ្រាន់ទៅវិញ។ អង្គជំនុំជម្រះសាលាដំបូងបានរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញលើ៖ សមភាពនៃមធ្យោបាយនៃការតទល់រឿងក្ដី, កិច្ចដំណើរការនីតិវិធីតទល់, កិច្ចដំណើរការនីតិវិធីដោយតម្លាភាព (ការរំលោភលើសិទ្ធិទទួលបានការពិនិត្យមើលឡើងវិញលើបណ្ដឹងឧទ្ធរណ៍), ការប្រព្រឹត្តិស្មើភាពគ្នា និងការជំនុំជម្រះក្ដីដោយតុលាការដែលមិនលំអៀង។ ទង្វើរបស់អង្គជំនុំជម្រះសាលាដំបូងបង្កើតបានជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការដោយចេតនាពិតប្រាកដ។ ក្រុមមេធាវីការពារក្ដីសូមយោងទៅ

---

[១] សំណើរបស់លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ E154។

[២] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សំណើរបស់លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ E154" ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ E154/1។

សារណាមុនៗ ដែលបានលើកអំណះអំណាងលើបញ្ហានេះ និងសារណាមុនៗមុនៗរបស់ខ្លួន ដែលពាក់ព័ន្ធនឹងបញ្ហានៃការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* (*ex parte*) [៣]។

## I. មូលដ្ឋាននៃបណ្តឹងសាទុក្ខ

*ក. ក្រមសីលធម៌ចៅក្រមកម្ពុជា និងក្រមសីលធម៌ឯទៀត ដែលអង្គជំនុំជម្រះសាលាដំបូងត្រូវគោរព ហាមឃាត់មិនឲ្យប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាង (ex parte) ឡើយ។ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង បានធ្វើការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាង (ex parte) ជាមួយភាគីមួយចំនួនប៉ុណ្ណោះ តាមការបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ដោយគាត់បានជូនដំណឹងដល់តែភាគីមួយចំនួនប៉ុណ្ណោះអំពីសាក្សីដែលអង្គជំនុំជម្រះសាលាដំបូង កំពុងពិចារណាកោះហៅ។ តើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនធ្វើការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាង (ex parte) ដែរឬទេ?*

*ខ. ច្បាប់អ.វ.ត.ក និងយុត្តិសាស្ត្រ កំណត់ថា ភាគីមានសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌ ដោយភាគីអាចឆ្លើយតបទៅនឹងសារណាដាក់ដោយភាគីឯទៀត។ អង្គជំនុំជម្រះសាលាដំបូងបានចេញបង្គាប់មិនឲ្យភាគីឆ្លើយតបនឹងសំណើនេះទេ។ តើអង្គជំនុំជម្រះសាលាដំបូងបានមានកំហុសដោយបង្គាប់មិនឲ្យភាគីធ្វើការឆ្លើយតប ដែរឬទេ?*

*ខ. ច្បាប់អ.វ.ត.ក និងយុត្តិសាស្ត្រ តម្រូវឲ្យសេចក្តីសម្រេចរបស់អង្គជំនុំជម្រះមានសំអាងហេតុ*

---

[៣] សំណើ, បណ្តឹងសាទុក្ខរបស់លោកអៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំសាលាដំបូងលើបណ្តឹងជិតជិតលោកស្រីចៅក្រម SILVIA CARTWRIGHT ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E137/5/1/1 ។ សំណើរបស់លោកអៀង សារី ស្នើឲ្យស៊ើបអង្កេតពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញា ជាមួយ លោកស្រីចៅក្រម SILVIA CARTWRIGHT ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E137/3។ បណ្តឹងតាមវិធានផ្ទៃក្នុង ៣៤ លើកទី២ របស់លោកអៀង សារី សុំប្តឹងជិតចិត្តចៅក្រម MARCEL LOMONDE និងការសុំចូលរួមក្នុងបណ្តឹងរបស់មេធាវីការពារក្តីអៀង ធីរិទ្ធ សុំប្តឹងជិតចិត្តសហចៅក្រមស៊ើបអង្កេត និងសំណើសុំឲ្យមានសវនាការជាសាធារណៈ MARCEL LOMONDE ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩,១។

*គ្រប់គ្រាន់។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសម្រេចលើសំណើនេះ តាមរយៈការចេញអនុស្សរណៈមួយដែលមិនមានសំអាងហេតុគ្រប់គ្រាន់។ តើអង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយបានចេញសេចក្តីសម្រេចនេះដែរឬទេ?*

## II. បញ្ហាជាបឋម

### ក. ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ

#### ១. អនុស្សរណៈជាសេចក្តីសម្រេចក្នុងគោលបំណងផ្សេងៗនៃវិធាន ១០៤

១. អនុលោមតាមវិធាន ១០៤ (១) អង្គជំនុំជម្រះតុលាការកំពូល ត្រូវសម្រេចលើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រម ឬសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ ទោះជាសេចក្តីសម្រេចនោះត្រូវបានធ្វើឡើងតាមរយៈអនុស្សរណៈមួយក៏ដោយ ក៏សេចក្តីសម្រេចដែលត្រូវបានជំទាស់នោះមានអានុភាពជាសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអាចប្តឹងសាទុក្ខបានដោយអនុលោមតាមវិធាន ១០៤[៤]។

២. ខ្លឹមសារ មានសារៈសំខាន់ជាងទម្រង់។ វិធានផ្ទៃក្នុងឆ្លុះបញ្ចាំងពីគោលបំណងអត្តនោម័តរបស់អ្នករៀបចំសេចក្តីព្រាង ជាជាងឆ្លុះបញ្ចាំងពីការពិតដោយសត្យានុម័ត។ ហេតុដូច្នេះហើយ វាជាក់ច្បាស់ថា វិធានផ្ទៃក្នុងប្រាកដជាត្រូវតែធ្វើការបកស្រាយ ដើម្បីសម្រេចគោលបំណងនេះ។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា សិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ អាចនឹងមិនត្រូវបានកាត់បន្ថយដោយផ្តល់សារៈសំខាន់លើទម្រង់ជាងខ្លឹមសារឡើយ។ ឧទាហរណ៍ កន្លងមក អង្គបុរេជំនុំជម្រះបានទទួល

---

[៤] អង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីសម្រេចជាទៀតទាត់តាមរយៈអនុស្សរណៈ។ នៅពេលដែលក្រុមមេធាវីការពារក្តី ស្នើសុំការបញ្ជាក់ផ្សេងៗ រួមទាំងថាតើអនុស្សរណៈដែលចុះហត្ថលេខដោយលោកនិល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែរឬទេ អង្គជំនុំជម្រះបានធ្វើការពន្យល់ (ក្នុងអនុស្សរណៈមួយ) ថា៖ “ទោះបីយើងឃើញមានភាពខុសគ្នាតិចតួចនៅក្នុងទម្រង់នៃសេចក្តីសម្រេចទាំងឡាយរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងក្តី ក៏តាមរយៈការអានសេចក្តីសម្រេចទាំងនេះ ធ្វើឱ្យយើងដឹងច្បាស់ថា សេចក្តីទាំងនេះត្រូវបានចេញដោយតាងនាមឲ្យអង្គជំនុំជម្រះទាំងមូល។ លើសពីនេះទៀត នេះជាទម្លាប់អនុវត្តទូទៅរបស់តុលាការកម្ពុជា និងតុលាការអន្តរជាតិឯទៀត។” *សូមមើល* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំលេខ E67, E57, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E74 ទំព័រទី ៣-៤។

យកបណ្តឹងឧទ្ធរណ៍មួយដែលធ្វើឡើងចំពោះសេចក្តីសម្រេចមួយនៅក្នុងសេចក្តីជូនដំណឹងរបស់ក្រឡាបញ្ជីស្តីពីការដាក់ឯកសារមិនគ្រប់គ្រាន់ បើទោះជាវិធានផ្ទៃក្នុងមិនបានចែងឱ្យបានជាក់លាក់អំពីការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការជូនដំណឹងអំពីការដាក់ឯកសារមិនគ្រប់គ្រាន់ក៏ដោយ។ អង្គបុរេជំនុំជម្រះ បានសម្រេចថា៖

> ទោះបីជាច្បាប់ជាធរមានពុំផ្តល់សិទ្ធិឱ្យបានជាក់លាក់ដល់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីជូនដំណឹងស្តីពីការដាក់ឯកសារពុំគ្រប់គ្រាន់ក្តី ក៏អង្គបុរេជំនុំជម្រះ បានសម្រេចតាមការសន្និដ្ឋានរបស់សហមេធាវីការពារក្តីថា វិធាន ២១ តម្រូវថាអង្គបុរេជំនុំជម្រះត្រូវបកស្រាយឱ្យបានទូលំទូលាយនូវសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថាសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ត្រូវបានគាំពារក្នុងកាលៈទេសៈនេះ។ ដោយហេតុថានេះជាបញ្ហាមួយពាក់ព័ន្ធនឹងគោលការណ៍ "ស្មើភាពចំពោះមុខច្បាប់" និង "សមភាពនៃមធ្យោបាយតទល់រឿងក្តី" ដោយគិតអំពីភារកិច្ចរបស់អង្គជំនុំជម្រះ ដូចបានចែងត្រង់វិធាន២១ នៃវិធានផ្ទៃក្នុង និងកាលៈទេសៈនៃបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះសម្រេចទទួលយកបណ្តឹងឧទ្ធរណ៍នេះ[៥]។

ការសម្រេចថាបណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាន ដោយហេតុថាសេចក្តីសម្រេចដែលត្រូវបានជំទាស់ ត្រូវបានចេញក្នុងទម្រង់ជាអនុស្សរណៈនោះ នឹងអនុញ្ញាតអង្គជំនុំជម្រះសាលាដំបូងរារាំងដោយចេតនាចំពោះលទ្ធភាពរបស់ភាគីក្នុងការដាក់បណ្តឹងសាទុក្ខលើសេចក្តីសម្រេចដែលមានប្រសិទ្ធិភាព តាមរយៈការចេញសេចក្តីសម្រេចដ៏ចម្រូងចម្រាស់ ដែលមានទម្រង់ជាអនុស្សរណៈនោះ។

## ២. បណ្តឹងសាទុក្ខនេះ អាចទទួលយកបានដោយអនុលោមតាមវិធាន ១០៤ និង វិធាន ២១

[៥] សាលដីកាលើបណ្តឹងលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ ១៣។

៣. អនុលោមតាមវិធាន១០៤ (១) អង្គជំនុំជម្រះតុលាការកំពូល "ត្រូវសម្រេចលើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនៃអង្គច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖ ក. កំហុសលើអង្គច្បាប់ដែលនាំឱ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ។ ឬ ខ. កំហុសនៃអង្គហេតុដែលនាំឱ្យសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ បន្ថែមពីនេះ បណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើបានដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។"

៤. បើសិនជាមានមន្ទិលសង្ស័យចំពោះភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនេះ ដោយអនុលោមតាមវិធាន ១០៤ នោះ វិធាន ២១ ដែលតម្រូវឱ្យវិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនជាប់ចោទ[៦] តម្រូវឱ្យទទួលយកបណ្តឹងសាទុក្ខនេះ។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ការអនុវត្តវិធាន ២១ និងបានលើកឡើងថា "ក្រោយពីបានពិចារណាលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍...អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ២១ តម្រូវឱ្យខ្លួនបកស្រាយវិធានផ្ទៃក្នុង តាមមធ្យោបាយដែលមានន័យថា បណ្តឹងឧទ្ធរណ៍នេះក៏អាចទទួលយកបានតាមមូលដ្ឋាននៃវិធាន ២១ ផងដែរ[៧]"។ អង្គជំនុំជម្រះតុលាការកំពូល គប្បីយល់ស្របចំពោះការបកស្រាយទូលំទូលាយចំពោះសិទ្ធិដាក់បណ្តឹងសាទុក្ខភ្លាមៗ។

## ក. វិធាន ១០៤ (១) កំហុសលើអង្គច្បាប់

---

[៦] វិធាន ២១ ចែងថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។"

[៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើសុំអនុញ្ញាតថតសម្លេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ A371/2/12 កថាខណ្ឌ ១៨។

៥. បណ្តឹងសាទុក្ខនេះ អាចទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤ (១) ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសលើអង្គច្បាប់ ដោយការខកខានមិនបានចេញដីកាសម្រេចដែលមានសំអាងហេតុគ្រប់គ្រាន់លើសំណើនេះ និងដោយការបង្គាប់មិនឱ្យភាគីឯទៀតឆ្លើយតបនឹងសំណើនេះ។ លោក អៀង សារី និងភាគី មានសិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុគ្រប់គ្រាន់ ហើយភាគីមានសិទ្ធិឆ្លើយតបនឹងសំណើនានា។ កំហុសលើអង្គច្បាប់ទាំងនេះនាំឱ្យមោឃៈសេចក្តីសម្រេចនេះ។

## ខ. វិធាន ១០៤ (១) កំហុសនៃអង្គហេតុ

៦. បណ្តឹងសាទុក្ខនេះ អាចទទួលយកបាន ដោយអនុលោមតាមវិធាន ១០៤(១) ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសលើអង្គហេតុ ដោយគ្រាន់តែបានចាត់ទុកសំណើនេះជាសំណើមួយ ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងជូនដំណឹងថា តើភាគីណាដែលអង្គជំនុំជម្រះសាលាដំបូងកំពុងពិចារណាឱ្យសួរសំណួរដល់ចម្លើយសាក្សីនីមួយៗនោះ។ ការអនុវត្តបែបនេះធ្វើឱ្យមានភាពមិនយុត្តិធម៌ ដោយហេតុថាវាអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងមើលរំលងការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ បណ្តាលមកពីការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* (*ex parte*) ហើយអង្គជំនុំជម្រះសាលាដំបូងបែរជាផ្តោតការយកចិត្តទុកដាក់លើសំអាងហេតុដែលខ្លួនយល់ឃើញថាមិនចាំបាច់ជូនដំណឹងជាមុនដល់ភាគីថា តើភាគីណាដែលត្រូវចាត់តាំងឱ្យសួរសំណួរសាក្សីនោះ។

## គ. វិធាន ១០៤ (១) ការរំលោភបំពានលើឆន្ទានុសិទ្ធិ

៧. បណ្តឹងសាទុក្ខនេះអាចទទួលយកបាន ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនតាមរយៈការបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងធ្វើការការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* (*ex parte*) ។ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចធានាថា បុគ្គលិករបស់ខ្លួនមិនរំលោភសិទ្ធិរបស់ភាគីក្នុងការទទួលបានការប្រព្រឹត្តិស្មើភាពគ្នា និងការជំនុំជម្រះក្តីដោយយុត្តិធម៌ ឬកាតព្វកិច្ចសីលធម៌របស់ចៅក្រម រួមទាំងកាតព្វកិច្ចជៀសវាងការការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* (*ex parte*)។

## ឃ. វិធាន ១០៤ (៤) ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ

៨. បណ្តឹងសាទុក្ខនេះ អាចទទួលយកបានដោយភ្លាមៗ ដោយហេតុថាវាពាក់ព័ន្ធនឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦)[៨]។ អនុលោមតាមវិធាន ១០៤ (៤) (ឃ) សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦) ត្រូវបានបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ។ វិធាន ៣៥ លើកឡើងអំពីសកម្មភាពនានាដែលអាចជាការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ប៉ុន្តែមិនលើកឡើងសកម្មភាពទាំងអស់ទេ[៩]។

៩. ថ្មីៗនេះ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា "គ្មានកំហុសអង្គច្បាប់ ឬអង្គហេតុ និងគ្មានការរំលោភនូវឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងណាមួយ ដែលបង្កើតបានជាការជ្រៀតជ្រែកដោយដឹង និងមានចេតនាទៅលើកិច្ចការរដ្ឋបាលតុលាការ ដោយយោងតាមអត្ថន័យនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ[១០]"។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូង មិនត្រឹមតែមានកំហុសលើអង្គច្បាប់ ឬមានកំហុសនៃអង្គហេតុទេ ឬរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនទេ ថែមទាំងជ្រៀតជ្រែកដោយមានចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ តាមរយៈការបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងចូលរួមក្នុងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* (*ex parte*)។ ការអនុវត្តដែលផ្ទុយពីសតិសម្បជញ្ញៈនេះ មានលក្ខណៈស្រដៀងគ្នា និងដូចគ្នាបើគិតពីកម្រិតធ្ងន់ធ្ងរទៅនឹងឧទាហរណ៍ផ្សេងៗនៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាល

---

[៨] ចំពោះការពិភាក្សាថាតើចៅក្រម អាចអនុវត្តតាមវិធាន ៣៥ (៦) *សូមមើល* បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្តឹងជិតចិត្តលោកស្រីចៅក្រម Silvia Cartwright ថ្ងៃទី ៥ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E137/5/1/1 កថាខណ្ឌ ៧-១០ ដែលក្រុមមេធាវីការពារក្តី សូមដាក់បញ្ចូលជាឯកសារយោង។

[៩] *សូមមើល* 002/14-12-2009-Extraordinary Chambers in the Courts of Cambodia/PTC (08) អង្គបុរេជំនុំជម្រះ បានស៊ើបអង្កេតការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះដែលអាចកើតមាន ពាក់ព័ន្ធនឹងការប្រព្រឹត្តដែល មិនបានចែងច្បាស់ក្នុងវិធាន ៣៥ (១) ពី (ក) ដល់ (ឆ)។

[១០] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១២ ឯកសារលេខ E130/4/3 ទំព័រ ១។

របស់អង្គជំនុំជម្រះក្នុងវិធាន៣៥[១១]។ មានន័យថា ការអនុវត្តនេះបង្ហាញពីការអនុវត្តមិនត្រឹមត្រូវ ដែលរំលោភទៅលើវិធានផ្ទៃក្នុង។

១០. លើសពីនេះទៀត សកម្មភាពរបស់អង្គជំនុំជម្រះសាលាដំបូង បង្កើតឱ្យមាន ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដោយចេតនាពិតប្រាកដ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងធ្វើការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង* (*ex parte*)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង បានរំលោភដោយចេតនាពិតប្រាកដលើ៖ **ក.** សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានដីកាសេចក្ដីដែលមានសំអាងហេតុគ្រប់គ្រាន់ (ដែលការពារសិទ្ធិរបស់គាត់ក្នុងការទទួលបានតម្លាភាព និងសិទ្ធិដាក់បណ្ដឹងឧទ្ធរណ៍), **ខ.** សិទ្ធិរបស់លោក អៀង សារី និងសិទ្ធិរបស់ភាគីឯទៀតក្នុង

---

[១១] វិធាន ៣៥ (១) ចែងថា៖

អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬ បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម:

ក-ផ្សាយចេញព័ត៌មានសម្ងាត់ ដោយរំលោភទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គ-ជំនុំជម្រះ។

ខ-ដោយគ្មានមូលហេតុសមស្រប បុគ្គលដែលមិនគោរពតាមសេចក្ដីបង្គាប់ឱ្យចូលរួមក្នុងដំណើរការជម្រះក្ដី ឬ មិនផ្ដល់ឯកសារ ឬ ភស្តុតាងផ្សេងទៀតឱ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំ-ជម្រះ។

គ-បំផ្លាញ ឬ កែក្លែងតាមមធ្យោបាយណាក៏ដោយលើឯកសារ វត្ថុតាង ឬ ភស្តុតាងដទៃទៀតដែលស្ថិតក្នុងសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញ។

ឃ-គំរាមកំហែង បំភិតបំភ័យ បង្ករបួសស្នាម ឬ ផ្ដល់សំណូក ឬ ក៏ជ្រៀតជ្រែកលើសាក្សីណាម្នាក់ ឬ លើ អ្នកដែលអាចក្លាយជាសាក្សីដែលកំពុងផ្ដល់ បានផ្ដល់ ឬ អាចផ្ដល់ភស្តុតាងដល់សហ-ចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។

ង-គំរាមកំហែង បំភិតបំភ័យ ឬសូកសំណូក ឬ ស្វែងរកវិធីគាបសង្កត់លើបុគ្គលដទៃទៀតក្នុងបំណងទប់ស្កាត់បុគ្គលនោះមិនឱ្យអនុវត្តតាមដីការបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។

ច-ជួយដោយចេតនា ដើម្បីឱ្យជនត្រូវចោទ ឬ ជនជាប់ចោទរត់គេចពីអំណាចយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ឬ

ឆ-ញុះញង់ ឬ ប៉ុនប៉ងប្រព្រឹត្តិអំពើណាមួយដូចមានចែងខាងលើ។

ការឆ្លើយតបទៅការអនុវត្តនានាដែលប៉ះពាល់ពួកគេ (ត្រូវបានការពារដោយសិទ្ធិសមភាពនៃមធ្យោបាយនៃការតទល់រឿងក្ដី និងកិច្ចដំណើរការនីតិវិធីតទល់) និង **គ.** សិទ្ធរបស់លោកអៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដោយមិនរងការប៉ះពាល់ដោយការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* (*ex parte*) (និងសិទ្ធិទទួលបានភាពស្មើគ្នានៅចំពោះមុខច្បាប់ និងសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយតុលាការដែលមិនលំអៀង)។

## ៣. បណ្ដឹងសាទុក្ខនេះ អាចទទួលយកបាន ដោយអនុលោមតាមតែវិធាន ២១

១១. បណ្ដឹងសាទុក្ខនេះអាចទទួលយកបានដោយភ្លាមៗ ដោយអនុលោមតាមតែវិធាន ២១ ប៉ុណ្ណោះ។ វិធាន២១ តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់លោក អៀង សារី។ កន្លងមក អង្គបុរេជំនុំជម្រះ បានសម្រេចថា វិធាន ២១ តម្រូវឱ្យអង្គបុរេជំនុំជម្រះទទួលយកបណ្ដឹងឧទ្ធរណ៍ ដើម្បីធានាថាសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ត្រូវបានការពារ ក្នុងករណីដែលមិនមានវិធានណាមួយផ្ដល់សិទ្ធិដាក់លាក់ក្នុងការដាក់បណ្ដឹងឧទ្ធរណ៍នោះ[១២]។ វាជាការរំលោភលើសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់លោកអៀង សារី បើសិនជាបណ្ដឹងសាទុក្ខនេះមិនអាចទទួលយកបាន។ មាត្រា ២ (៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវគោរព និងគាំពា យោងតាមរដ្ឋធម្មនុញ្ញ[១៣] ចែងថា "រដ្ឋនៃកតិកាសញ្ញានេះត្រូវ៖ ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឱ្យមានការដោះស្រាយដោយស័ក្ដិសិទ្ធិ ទោះបីការរំលោភនោះ

---

[១២] *សូមមើល* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោកអៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦ និងសេចក្ដីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើការនីតិវិធី ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១០ ឯកសារលេខ D390/1/2/4 កថាខណ្ឌ ១៣។

[១៣] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនសព្រះរាជាណាចក្រកម្ពុជា វិសោធនកម្មក្នុងឆ្នាំ ១៩៩៩ ចែងថាព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

បានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ”។ លោក អៀង សារី នឹងមិនទទួលបានការដោះស្រាយដោយមានប្រសិទ្ធិភាពឡើយ បើសិនជាបណ្តឹងសាទុក្ខនេះមិនអាចទទួលយកបាននៅក្នុងដំណាក់កាលនេះ ហើយបើសិនអង្គជំនុំជម្រះសាលាដំបូងបន្តទង្វើរបស់ខ្លួនដែលបានអនុវត្តកន្លងមក[១៤] ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងទំនងជានៅតែបង្គាប់មិនឱ្យភាគីឆ្លើយតបនឹងសំណើមួយចំនួន បន្តចេញអនុស្សរណៈដែលមិនមានសំអាងហេតុគ្រប់គ្រាន់ ហើយអ្វីដែលធ្ងន់ធ្ងរបំផុតនោះគឺនៅតែបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងធ្វើការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង* (*ex parte*) និងផ្តល់សេចក្តីជូនដំណឹងជាមុខទាក់ទងនឹងព័ត៌មានសំខាន់ៗស្តីពីការរៀបចំសវនាការឱ្យភាគីឯទៀតតែប៉ុណ្ណោះ។ ទង្វើទាំងនេះប៉ះពាល់ដល់សិទ្ធិរបស់លោក អៀង សារី។

---

[១៤] *សូមមើល* ឧទាហរណ៍ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹង “ការកត់សម្គាល់” របស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១១ (ឯកសារ E130) ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ (ឯកសារ E130/3) (ចេញ ក្នុង ទម្រង់ជាអនុស្សរណៈ និងបង្គាប់មិនឱ្យភាគីធ្វើការឆ្លើយតប), ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើរបស់ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំធ្វើសេចក្តីថ្លែងការណ៍បឋមត្រួសៗជំនួសមុខឱ្យដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ E131/4/) ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ឯកសារ E131/4/1) (ចេញក្នុងទម្រង់ជាអនុស្សរណៈ និងបង្គាប់មិនឱ្យភាគីធ្វើការឆ្លើយតប), អនុស្សរណៈឆ្លើយតបទៅនឹងសំណើដែលបានដាក់ដោយមេធាវីការពារអៀង សារី (ឯកសារ E53/2/) ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ (ឯកសារ E53/2/1) (ចេញក្នុងទម្រង់ជាអនុស្សរណៈ និងបង្គាប់មិនឱ្យភាគីធ្វើការឆ្លើយតប), អនុស្សរណៈស្តីពីសេចក្តីសម្រេចលើសំណើរបស់អៀង សារី ស្នើសុំដាក់សំណើឱ្យមាន “ការបញ្ជាក់ថាគាត់នឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញនូវទឡ្ហីករណ៍ផ្ទាល់មាត់ នៅពេលសវនាការបឋមស្តីពីអញ្ញត្រកម្មនីមួយៗរបស់គាត់” ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ (ឯកសារ E65/1) (ចេញក្នុងទម្រង់ជាអនុស្សរណៈ និងបង្គាប់មិនឱ្យភាគីធ្វើការឆ្លើយតប), សេចក្តីសម្រេចលើសំណើរបស់នួន ជា សុំបំពេញកិច្ចស៊ើបសួរតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង បន្ទាប់ពីមានការបញ្ចេញឯកសារសម្ងាត់នានាដោយគ្មានការអនុញ្ញាត ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ (ឯកសារ E147/1) (ចេញក្នុងទម្រង់ជាអនុស្សរណៈ និងបង្គាប់មិនឱ្យភាគីធ្វើការឆ្លើយតប), សេចក្តីសម្រេចលើញត្តិរបស់អៀង សារី សុំឱ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ (ឯកសារ E71/1) (ចេញក្នុងទម្រង់ជាអនុស្សរណៈ និងបង្គាប់មិនឱ្យភាគីធ្វើការឆ្លើយតប), សេចក្តីសម្រេចលើសំណើរបស់អៀង សារី ទាក់ទិននឹងការយកអង្គហេតុពីសំណុំរឿង ០០១ ដែលបានវិនិច្ឆ័យហើយ និងអង្គហេតុនៃការដឹងឮជាទូទៅមកអនុវត្តក្នុងសំណុំរឿង ០០២ ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១ (ឯកសារ E69/1) (ចេញក្នុងទម្រង់ជាសេចក្តីសម្រេច និងបង្គាប់មិនឱ្យភាគីធ្វើការឆ្លើយតប)

### ខ. សំណើឱ្យមានសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ

១២. ក្រុមមេធាវីការពារក្តីស្នើឱ្យមានការធ្វើសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងក្នុងបណ្តឹងសាទុក្ខនេះ។ វិធាន ១០៩ (១) បញ្ជាក់ថា សវនាការលើបណ្តឹងសាទុក្ខ ជាទូទៅគប្បីធ្វើឡើងជាសាធារណៈ[១៥]។ បណ្តឹងសាទុក្ខនេះមានអនុភាពលើសិទ្ធិជាសារវ័ន្តរបស់ លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ បញ្ហាដែលបានលើកឡើង មិនមែនជាបញ្ហាសម្ងាត់ឡើយ។

## III. សាវតារ

១៣. កាលពីថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តី ទទួលដំណឹងក្រៅផ្លូវការពីក្រុមមេធាវីការពារក្តីមួយក្រុមថាមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង បានទាក់ទងមេធាវីការពារក្តី លោក នួន ជា និងលោក ខៀវ សំផន និងបានជម្រាបពួកគាត់អំពីក្រុមបន្ទាប់នៃអ្នកជំនាញ និងសាក្សី ដែលអង្គជំនុំជម្រះសាលាដំបូង កំពុងពិចារណាកោះហៅឱ្យផ្តល់សក្ខីកម្ម ហើយបានសួរក្រុមមេធាវីការពារក្តីទាំងពីរក្រុមនេះថាតើក្រុមទាំងពីរនេះ មានចំណាប់អារម្មណ៍ដឹកនាំសួរដេញដោលសាក្សីដែរឬទេ។ បន្ទាប់ពីទទួលបានព័ត៌មាននេះភ្លាម ក្រុមមេធាវីការពារក្តីបានផ្ញើសារអេឡិកត្រូនិកជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដោយចម្លងជូនភាគីទាំងអស់ ដើម្បីសួរបញ្ជាក់ថាតើព័ត៌មាននេះ ពិតប្រាកដដែរឬទេ និងជាពិសេស សួរបញ្ជាក់ថាតើគាត់អាចជូនដំណឹងដល់ភាគីដែរឬទេ បើសិនជាសាក្សីជំនាញណាមួយ យល់ព្រមផ្តល់សក្ខីកម្ម[១៦]។

---

[15] វិធាន ១០៩ (១) លើកឡើងថា: "សវនាការនៃអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើឡើងជាសាធារណៈ។ អង្គជំនុំជម្រះតុលាការកំពូលអាចធ្វើសេចក្តីសម្រេចពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍ ដែលដាក់ដោយភាគីតែប៉ុណ្ណោះ"។

[១៦] សារអេឡិចត្រូនិកពី Tanya Pettay ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចម្លងជូនភាគីទាំងអស់ មានចំណងជើង "សាក្សីក្រុមបន្ទាប់របស់អង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១

១៤. កាលពីថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង បានឆ្លើយតបថា៖

អង្គជំនុំជម្រះសាលាដំបូងកំពុងពិចារណាកោះហៅសាក្សីដែលមានរាយឈ្មោះខាងក្រោមនេះ សម្រាប់ការជំនុំជម្រះក្តីក្នុងដំណាក់កាលបន្ទាប់។ សាក្សីទាំងនោះត្រូវបានកោះហៅដោយភាគីផ្សេងៗគ្នា ក្នុងនោះមាន ក.ស.ព ក្រុមមេធាវីការពារក្តីលោក នួន ជា និងក្រុមមេធាវីការពារក្តី លោក ខៀវ សំផន។ ខ្ញុំបានទាក់ទងក្រុមមេធាវីការពារក្តីលោក នួន ជា និងក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីសួរពួកគាត់ថាតើពួកគាត់មានចំណាប់អារម្មណ៍ដឹកនាំការសួរដេញដោលសាក្សីទាំងនេះដែរឬទេ។

អង្គជំនុំជម្រះសាលាដំបូង នឹងធ្វើការសម្រេចថាតើសាក្សី និងអ្នកជំនាញណាដែលត្រូវកោះហៅសម្រាប់ដំណាក់កាលបន្ទាប់ និងភាគីណាដែលត្រូវប្រគល់សិទ្ធិឱ្យសួរដេញដោល នៅពេលខ្លីខាងមុខនេះ។ ភាគីទាំងអស់ នឹងទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចនេះឱ្យបានឆាប់តាមតែអាចធ្វើបាន[១៧]។

១៥. មេធាវីការពារក្តីបានធ្វើការឆ្លើយតបថា៖

លោក អាង ឧត្តម និងលោក Karnavas សូមបញ្ជាក់ជាថ្មី[១៨] (សូមពិនិត្យសារ

---

[១៧] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង Tanya Pettay ផ្ញើជូន Tanya Pettay ចម្លងជូនភាគីទាំងអស់ មានចំណងជើង "យោង៖ សាក្សីក្រុមបន្ទាប់របស់អង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១

[១៨] មេធាវីការពារក្តីយល់ឃើញថា ជាការចាំបាច់ដែលត្រូវ "បញ្ជាក់សាជាថ្មី" ចំពោះចំណុចនេះទៅកាន់ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយសារថា នេះពុំមែនជាលើកទីមួយដែលមន្ត្រីច្បាប់រូបនេះបានផ្តល់ព័ត៌មានសំខាន់ទាក់ទិននឹងការរៀបចំសវនាការតែចំពោះភាគីមួយចំនួនតែប៉ុណ្ណោះ។ មេធាវីការពារក្តីបានដឹងករណីបែបនេះនៅពេលបានទទួលដំណឹងកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១ ថា មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដោយផ្ទាល់មាត់ទៅកាន់សមាជិកម្នាក់នៃក្រុមមេធាវីការពារទាំងអស់អំពីកាលបរិច្ឆេទចាប់ផ្តើមសវនាការលើអង្គសេចក្តី។ ក្រោយពីបានទទួលព័ត៌មាននេះភ្លាម សហមេធាវីអន្តរជាតិលោក Michael G. Karnavas បានផ្ញើសារអេឡិចត្រូនិកមួយច្បាប់ជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយបានចម្លងជូនភាគីទាំងអស់ ដោយបានលើកឡើងថា៖

យើងយល់ថាលោកស្រីបានបង្ហើបប្រាប់បុគ្គលមួយចំនួនថា នាពេលឆាប់ៗខាងមុខ យើងនឹងបានទទួលដីកាកំណត់កាលបរិច្ឆេទសវនាការមួយ ដែលកំណត់យកថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ជាថ្ងៃសវនាការ

> លើអង្គសេចក្ដី។ យើងក៏បានឮពាក្យចចាមអារ៉ាមទៀតថាសេចក្ដីសន្និដ្ឋានចោទប្រកាន់ទំនងជាធ្វើនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ដើម្បីតម្លាភាព ពិសេសដោយសារមានការរិះគន់ជាហូរហែរមកលើ អ.វ.ត.ក (ភាគច្រើនដោយសារ ការបែកធ្លាយព័ត៌មានផ្ទៃក្នុង) ទើបយើងចង់ឲ្យមានដីកាកំណត់កាលបរិច្ឆេទត្រឹមត្រូវ ដែលមានហត្ថលេខារបស់ចៅក្រមប្រធាន ឬលិខិតរបស់លោកស្រីជូនដំណឹងឲ្យភាគីទាំងអស់បានជ្រាប។ ខ្ញុំគិតថាការចែករម្លែកព័ត៌មានដល់មនុស្សមួយចំនួនក្រៅផ្លូវការ ធ្វើឲ្យមានការបាត់ទំនុកចិត្តលើកិច្ចដំណើរការនីតិវិធី។ ខ្ញុំសូមអភ័យទោសចំពោះការដែលខ្ញុំនិយាយចំៗ។ ខ្ញុំជឿជាក់ថាលោកស្រីនឹងយល់អំពីកង្វល់របស់ខ្ញុំ ដោយសារយើងមានបញ្ហាសំខាន់ៗជាច្រើននៅក្នុងសំណុំរឿងនេះ ដែលត្រូវដោះស្រាយមុនពេលសវនាការ ហើយខ្ញុំពុំចូលចិត្តការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* ឡើយ។

សារអេឡិចត្រូនិកពីលោក Karnavas ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយបានចម្លងជូនគ្រប់ភាគីទាំងអស់មានចំណងជើងថា៖ “កាលបរិច្ឆេទចាប់ផ្ដើមដំណើរការជំនុំជម្រះក្ដី” ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។ បន្ទាប់ពីបានផ្ញើសារអេឡិចត្រូនិកនេះចេញបន្តិច មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានផ្ញើសារអេឡិចត្រូនិកមួយទៅកាន់គ្រប់ភាគីទាំងអស់ ដោយបានផ្ដល់ព័ត៌មានពីកាលបរិច្ឆេទចាប់ផ្ដើមដំណើរការជំនុំជម្រះក្ដី។ សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងផ្ញើភាគីទាំងអស់មានចំណងជើងថា “លិខិតប្រាស្រ័យទាក់ទងការងារជាមួយភាគីក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងការជំនុំជម្រះលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២ និងព័ត៌មានមុនពេលសវនាការនៅថ្ងៃទី ១៩-២០ ខែ តុលា ឆ្នាំ ២០១១” ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។ គាត់បានឆ្លើយតបក្នុងសារដោយឡែកមួយមកលោក Karnavas នៅថ្ងៃដដែលនោះ ដូចតទៅ៖

> សារអេឡិចត្រូនិកមួយដែលបានផ្ដល់សេចក្ដីសង្ខេបលម្អិតលើបញ្ហាទាំងអស់ ពាក់ព័ន្ធនឹងការរៀបចំសវនាការដំណាក់កាលដំបូង ត្រូវបានផ្ញើទៅភាគីទាំងអស់កាលពីព្រឹកមិញ។ មុនពេលចេញលិខិតនេះបន្តិច ព័ត៌មានមួយចំនួននៅក្នុងលិខិតនោះត្រូវបានចែករំលែកដោយសម្ងាត់សម្រាំងទៅបុគ្គលមួយចំនួនតូចតែប៉ុណ្ណោះ (ឧទាហរណ៍ ប្រធានស្ដីពីនៃផ្នែកគាំពារការពារក្ដី អង្គភាពគាំពារសាក្សី និងអ្នកជំនាញ និង តាមអង្គភាព និងមន្ត្រីសំខាន់ៗផ្សេងៗ) ដែលអាចជួយដល់ប្រសិទ្ធភាពនៃការរៀបចំសវនាការ។ នាងខ្ញុំធ្លាប់បានបញ្ជាក់រួចមកហើយថា នាងខ្ញុំជាជនបង្គោលសម្រាប់ការប្រាស្រ័យទាក់ទងរវាងភាគី និងអង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុនេះ សូមលោកមេត្តាកុំផ្ញើលិខិតប្រភេទនោះដោយចម្លងជូនចៅក្រមអង្គជំនុំជម្រះសាលាដំបូង។

សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងផ្ញើជូនលោក Karnavas ដែលបានចម្លងជូនគ្រប់ភាគីទាំងអស់ មានចំណងជើងថា៖ “កម្មវត្ថុ៖ កាលបរិច្ឆេទនៃការចាប់ផ្ដើមសវនាការ” ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។ លោក Karnavas បានឆ្លើយតបថា៖

> សូមអរគុណដែលលោកស្រីបានឆ្លើយតបបានឆាប់រហ័ស។ នៅក្នុងលិខិតរបស់លោកស្រី ពាក្យសំខាន់គឺពាក្យថា “សម្ងាត់សម្រាំង”។ ខ្ញុំ និងលោក អាង ឧត្ដម ជាតំណាងរបស់លោក អៀង សារី។ ឬនិយាយម្យ៉ាងទៀត យើងជាភាគី។ ទោះបីផ្នែកគាំពារការការពារក្ដីមានមុខងារសំខាន់យ៉ាងណាក៏ដោយ ក៏អង្គភាព

**បណ្ដឹងសាទុក្ខរបស់លោកអៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់លោកអៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធ**

អេឡិចត្រូនិករបស់លោក Karnavas ផ្ញើជូនលោកស្រីកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១) អំពីការព្រួយបារម្ភអំពីការដឹងពីប្រភពដទៃថា មានការប្រាស្រ័យទាក់ទងការងាររវាងលោកស្រី និងក្រុមមេធាវីការពារក្ដីផ្សេងពាក់ព័ន្ធនឹងសាក្សី និងបញ្ជាក់កំណត់កាលបរិច្ឆេទសវនាការនៅថ្ងៃមុខ។ ភាគីទាំងអស់ត្រូវទទួលបានការជូនដំណឹង ពោលគឺពុំមែនតែភាគីមួយចំនួនតូចប៉ុណ្ណោះទេ ទោះបីពួកគេពុំអាចជាអ្នកសួរសំណួរក៏ដោយ។ ប្រសិនបើមានហេតុផលណាមួយដែលលោកស្រីយល់ថា ចាំបាច់តែត្រូវបន្តការប្រាស្រ័យទាក់ទងជាមួយតែភាគីមួយចំនួន សូមបញ្ជាក់អំពីមូលហេតុ ដើម្បីយើងអាចដាក់អ្វីមួយទៅអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងទង្វើដែលគ្មានតម្លាភាពបែបនេះ។ នៅឯតុលាការផ្សេងឯទៀត ក៏ពុំធ្លាប់មានការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង*បែបនេះដែរ[១៩]។

១៦. មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានធ្វើការឆ្លើយតបថា៖

នាងខ្ញុំសូមបញ្ជាក់ច្បាស់ថា ការប្រាស្រ័យទាក់ទងការងារដែលលោកបានលើកឡើង ពុំពាក់ព័ន្ធនឹងមេធាវីការពារក្ដី អៀង សារី ឬភាគីណាមួយផ្សេងដែលមានបញ្ជាក់ក្នុងសារអេឡិចត្រូនិកនោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការចាត់តាំង

---

នេះពុំមែន ពុំអាច ហើយក៏នឹងពុំតំណាងឱ្យលោក អៀង សារី បានឡើយ ហើយ "បុគ្គលមួយចំនួនតូច" ដែលលោកស្រីជ្រើសរើស "សម្រិតសម្រាំង" នោះក៏ពុំតំណាងឱ្យលោក អៀង សារី ដែរ។ ដូច្នេះ នេះហើយជាកង្វល់របស់ខ្ញុំ។

សារអេឡិចត្រូនិកពីលោក Karnavas ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយចម្លងជូនគ្រប់ភាគីទាំងអស់ មានចំណងជើងថា៖ "កម្មវត្ថុ៖ កាលបរិច្ឆេទនៃការចាប់ផ្ដើមសវនាការ" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបទៅនឹងសារអេឡិចត្រូនិកនេះថា៖ "នាងខ្ញុំអាចបញ្ជាក់ជូនលោកថា ភាគីទាំងអស់បានទទួលការជូនដំណឹងអំពីបញ្ហាទាំងអស់បានឆាប់រហ័ស ហើយពុំមានភាគីណាមួយខូចប្រយោជន៍ដោយសារការកំហិតព័ត៌មាននាពេលកន្លងដែលនាងខ្ញុំបានលើកឡើងនោះឡើយ (ដែលបានកើតឡើងមុនពេលសាររួមផ្ញើទៅភាគីទាំងអស់)"។ សារអេឡិចត្រូនិកទីពីរពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយចម្លងជូនគ្រប់ភាគីទាំងអស់ មានចំណងជើងថា៖ "កម្មវត្ថុ៖ កាលបរិច្ឆេទនៃការចាប់ផ្ដើមសវនាការ" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។

[១៩] សារអេឡិចត្រូនិកពីលោកស្រី Tanya Pettay ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយចម្លងជូនគ្រប់ភាគីទាំងអស់ មានចំណងជើងថា៖ "កម្មវត្ថុ៖ បញ្ជីឈ្មោះសាក្សីដែលអង្គជំនុំជម្រះសាលាដំបូងនឹងកោះហៅនាពេលបន្ទាប់" ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១។

ភារកិច្ចទទួលខុសត្រូវក្នុងការសួរសំណួរទៅភាគីតាមការសមស្រប និងមនុស្សដែលអាចក្លាយជាសាក្សីក្រោមការពិចារណា ត្រូវបានដាក់បញ្ចូលតែក្នុងបញ្ជីសាក្សីរបស់ ក.ស.ព និងក្រុមមេធាវីការពារក្តីចំនួន ២ ក្រុមប៉ុណ្ណោះ។ ជំហានដំបូងក្នុងការអនុវត្តឆន្ទានុសិទ្ធិនេះ គឺដើម្បីបញ្ជាក់ថា តើក្រុមមេធាវីការពារក្តីទាំង ២ នេះ ឬ ក.ស.ព អាចមានឆន្ទៈបំពេញភារកិច្ចនេះដែរឬទេ។ មេធាវីការពារក្តីជនជាប់ចោទ អៀង សារី ឬភាគីណាមួយផ្សេងទៀត ពុំអាចបញ្ចេញយោបល់ពាក់ព័ន្ធនឹងបញ្ហាថាតើ នួន ជា ឬ ខៀវ សំផន មានបំណងសួរសាក្សីដែលមានឈ្មោះក្នុងបញ្ជីឈ្មោះសាក្សីរបស់ពួកគេទេ។

ជាការត្រឹមត្រូវដែលលោកមានប្រសាសន៍ថា នៅតុលាការដទៃទៀត មិនមែនបុគ្គលទាំងអស់ដែលស្ថិតក្នុងតួនាទីរបស់នាងខ្ញុំ សុទ្ធតែចាត់វិធានការបង្ការជាមុនពាក់ព័ន្ធនឹងការរៀបចំសវនាការដូចនាងខ្ញុំកំពុងធ្វើឡើយ។ កិច្ចការនេះផ្តល់ជាប្រយោជន៍ក្នុងក្របខណ្ឌការរៀបចំប្រកបដោយប្រសិទ្ធភាព និងជាប្រយោជន៍ដល់ភាគី[២០]។

១៧. សហមេធាវីនាំមុខតំណាងដើម្បីបណ្តឹងរដ្ឋប្បវេណីបានធ្វើការឆ្លើយតបទៅនឹងសារអេឡិចត្រូនិកជាហូរហែទាំងនេះ ដើម្បីជូនដំណឹងដល់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងថា ពួកគេពិតជាចង់បានព័ត៌មានពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងការងារទាំងនេះ “ដើម្បីឱ្យយល់ពីលក្ខណៈវិនិច្ឆ័យដែលអង្គជំនុំជម្រះយកមកប្រើ ក្នុងការផ្តល់នូវការទទួលខុសត្រូវចម្បងដល់ភាគីណាមួយសម្រាប់ការសាកសួរនាំមុខ និងសម្រាប់តម្លាភាពផង”[២១]។

១៨. នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានរៀបចំកិច្ច

---

[២០] សារអេឡិចត្រូនិកទីពីរពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនលោកស្រី Pettay ដោយចម្លងជូនគ្រប់ភាគីទាំងអស់ មានចំណងជើងថា៖ “កម្មវត្ថុ៖ បញ្ជីឈ្មោះសាក្សីដែលអង្គជំនុំជម្រះសាលាដំបូងនឹងកោះហៅនាពេលបន្ទាប់” ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១១។

[២១] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី Jeanne Sulzer ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយចម្លងជូនគ្រប់ភាគីទាំងអស់ មានចំណងជើងថា៖ “កម្មវត្ថុ៖ បញ្ជីឈ្មោះសាក្សីដែលអង្គជំនុំជម្រះសាលាដំបូងនឹងកោះហៅនាពេលបន្ទាប់” ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១។

ប្រជុំរៀបចំសវនាការក្រៅផ្លូវការមួយជាមួយភាគី។ នៅក្នុងកិច្ចប្រជុំនោះ សហមេធាវីនាំមុខតំណាងដើម្បីបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងចម្លងជូនគ្រប់ភាគីទាំងអស់នូវការប្រាស្រ័យទាក់ទងការងាររបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ។ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា គាត់ពុំអាចធ្វើបែបនេះបានទេ តែគាត់អាចនឹងចម្លងជូនដល់ភាគីណាដែលគាត់យល់ថាពាក់ព័ន្ធនឹងបញ្ហានោះប៉ុណ្ណោះ។ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា ការចម្លងជូនគ្រប់ភាគីទាំងអស់នឹងបង្កើនការងារកាន់តែច្រើនដល់រូបគាត់ ដោយសារថានៅពេលគាត់បញ្ជូនសារអេឡិចត្រូនិកទូទៅទៅកាន់គ្រប់ភាគីទាំងអស់ គាត់បានទទួលសារឆ្លើយតបវិញជាច្រើនសន្ធឹកសន្ធាប់។

១៩. នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១១ មេធាវីការពារក្តីបានចែកជូនសេចក្តីជូនដំណឹងក្រៅផ្លូវការនៃសំណើដែលបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនរក្សាការប្រាស្រ័យទាក់ទងការងារដោយចំហ និងមានតម្លាភាពជាមួយគ្រប់ភាគីទាំងអស់ ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ។ សំណើនេះបានពន្យល់ថា សំណើនេះត្រូវបានធ្វើឡើង ដោយសារមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានចូលរួមក្នុងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* ជាមួយភាគីមួយចំនួនប៉ុណ្ណោះ ពាក់ព័ន្ធនឹងបញ្ហានានាដែលមានសារៈសំខាន់ដល់គ្រប់ភាគីទាំងអស់។ សំណើនេះបានពណ៌នានូវការប្រាស្រ័យទាក់ទងការងារដែលបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើ រួមទាំងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* របស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងដែលបានលើកឡើងខាងលើ[២២]។

២០. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ មេធាវីការពារក្តីបានដាក់សំណើនេះ។ សំណៅនៃសំណើដែលដាក់ដូចគ្នាបេះបិទទៅនឹងសំណៅដែលបានចែកជូនក្រៅផ្លូវការ លើកលែងតែថាសំណៅក្រៅផ្លូវការនោះបានដាក់កាលបរិច្ឆេទនៃការដាក់នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ តែដោយសារមានការពន្យារ

---

[២២] *សូមមើល ជើងទំព័រខាងលើ* លេខ ១៨។

ពេលដោយពុំមានរំពឹងទុកមុនដោយសារការបកប្រែជាភាសាខ្មែរនោះ សំណើនេះត្រូវបានដាក់មួយថ្ងៃបន្ទាប់វិញ។

២១. នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលត្រូវបានជំទាស់ ដោយអះអាងថា៖

> [សំណើសុំនេះ] ធ្វើឡើងបន្ទាប់ពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានផ្ញើលិខិតទៅក្រុមមេធាវីការពារក្តីចំនួន ២ ក្រុម ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មបុគ្គលដែលអាចធ្វើជាសាក្សី ដើម្បីឱ្យដឹងថា តើមេធាវីការពារក្តីពិតជាមានបំណងសួរសំណួរសាក្សីទាំងនេះដែរ ឬយ៉ាងណា ក្នុងករណីដែលសាក្សីទាំងនេះត្រូវបានអង្គជំនុំជម្រះសម្រេចកោះហៅ។ សំណើសុំខាងលើគឺជំទាស់ទៅនឹងសារអេឡិចត្រូនិកដែលកំហិតត្រឹមតែភាគីមួយចំនួនតូចដោយសំអាងថា "ភាគីដទៃអាចមានបំណងបញ្ចេញយោបល់ពាក់ព័ន្ធនឹងភាគីណាមួយ ដែលត្រូវសួរសាក្សីណាម្នាក់ ឬពាក់ព័ន្ធនឹងបញ្ហាផ្សេងៗ" (កថាខណ្ឌ ១២)[២៣]។

អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា "ជាទម្លាប់អនុវត្ត អង្គជំនុំជម្រះសាលាដំបូងតែងតែងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់រៀបចំសេចក្តីព្រាងអនុស្សរណៈសម្រាប់អង្គជំនុំជម្រះពិនិត្យពិចារណា ឬអនុម័ត។ អនុលោមតាមទម្លាប់អនុវត្តនេះ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើលិខិតប្រាស្រ័យទាក់ទងការងារដែលមេធាវីការពារក្តីបានលើកឡើង"[២៤]។ បន្ទាប់មកអង្គជំនុំជម្រះបានអះអាងថា "ជាការសមស្របដែលលិខិតប្រាស្រ័យទាក់ទងការងារនោះត្រូវបានមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើជូនទៅភាគីពាក់ព័ន្ធដែលមានរាយនាមក្នុងលិខិតនោះ"[២៥] និង "អង្គជំនុំជម្រះនឹងពុំឆ្លើយតបទៅនឹងសំណើប្រភេទនេះទៀតឡើយ និងអាចចាត់ទុកសំណើប្រភេទនេះជាចេតនាព្យាយាមអូសបន្លាយកិច្ចដំណើរការនីតិវិធី"[២៦]។ អង្គជំនុំជម្រះបានបង្គាប់ភាគីឈប់ធ្វើការឆ្លើយតប

---

[២៣] សេចក្តីសម្រេចដែលត្រូវបានជំទាស់, ទំព័រ ១។

[២៤] *ដូចដើងទំព័រខាងលើ*។

[២៥] *ដូចដើងទំព័រខាងលើ*។

[២៦] *ដូចដើងទំព័រខាងលើ*, ទំព័រ ២។

ទៅនឹងសំណើនេះ[២៧]។ ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា សំណើនេះពុំមែនជាសំណើបន្ទាន់ទេ និងមិនគួរត្រូវបានធ្វើចេញក្រៅផ្លូវការជាមុនដែរ។ អង្គជំនុំជម្រះបានកត់សម្គាល់ថា "សេចក្តីជូនដំណឹងក្រៅផ្លូវការជាមុនដែលភាគីបានដាក់តែ ១ ភាសា (ដោយសារបញ្ហាជាប់គាំងការបកប្រែភាសា) ពេលខ្លះខុសប្លែកច្រើនពីសេចក្តីជូនដំណឹងដែលភាគីបានដាក់នៅពេលក្រោយមកទៀត។ ចំណុចនេះប៉ះពាល់ដល់ប្រសិទ្ធភាពការងាររបស់ភាគីដទៃទៀត ឬរបស់អង្គជំនុំជម្រះ។ ភាគីដែលបន្តអនុវត្តទម្លាប់មិនត្រឹមត្រូវបែបនេះនឹងត្រូវអង្គជំនុំជម្រះដកហូតឱកាសក្នុងការដាក់សេចក្តីជូនដំណឹងក្រៅផ្លូវការជាមុនអំពីសំណើរបស់ខ្លួនមកអង្គជំនុំជម្រះ ..."[២៨]។

## V. ឥន្ទ្រីករណ៍ និងអង្គច្បាប់

*"គេនិយាយថា ពន្លឺថ្ងៃជាធាតុដ៏ល្អបំផុតក្នុងការសម្លាប់មេរោគ"*

ប្រសាសន៍របស់ចៅក្រម Louis D. Brandeis នៃតុលាការកំពូលសហរដ្ឋអាមេរិក[២៩]

### ក. អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន និងបានជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ដោយណែនាំឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនចូលរួមក្នុងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង*

២២. លោក អៀង សារី មានសិទ្ធិជាសារវ័ន្តក្នុងការចូលរួមការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលត្រូវប្រព្រឹត្តឱ្យបានស្មើគ្នាដូចជនជាប់ចោទដទៃទៀត និងសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការដែលមិនលម្អៀង[៣០]។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា៖ "ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះ

---

[២៧] *ដូចជើងទំព័រខាងលើ*។

[២៨] *ដូចជើងទំព័រខាងលើ*។

[២៩] ដូចដែលត្រូវបានថ្លែងដោយចៅក្រមតុលាការកំពូលសហរដ្ឋអាមេរិក Louis Brandeis នៅក្នុង៖ LOUIS D. BRANDEIS, OTHER PEOPLE'S MONEY, ជំពូកទី៥ (ឆ្នាំ ១៩១៣) *អាចរកបាននៅគេហទំព័រ៖* http://www.law.louisville.edu/library/collections/brandeis/node/191។

[៣០] បើតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងចែងថា៖ "សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។

**បណ្តឹងសាទុក្ខរបស់លោកអៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធ**

មុខច្បាប់ ...”។ មាត្រា ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា៖ “បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ”។ មាត្រា ៧ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ដែលត្រូវបញ្ចូលយ៉ាងច្បាស់លាស់ទៅក្នុងរដ្ឋធម្មនុញ្ញ[៣១] ចែងថា៖ “មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង។ មនុស្សគ្រប់រូបមានសិទ្ធិទទួលការការពារស្មើៗគ្នាប្រឆាំងនឹងការរើសអើងណា ដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឲ្យមានការរើសអើង”។ មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”) ចែងថា៖ “ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី”។ មាត្រា ២៦ ចែងថា៖ “ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិការពារពីច្បាប់ស្មើគ្នា ដោយឥតរើសអើង”។

២៣. ការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* រំលោភទៅលើសិទ្ធិទាំងនេះដែលត្រូវប្រព្រឹត្តឲ្យបានស្មើគ្នាដូចជនជាប់ចោទដទៃទៀត និងសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការដែលមិនលម្អៀង។ ការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* ធ្វើឲ្យភាគីនានាត្រូវបានប្រព្រឹត្តចំពោះដោយមិនបានស្មើគ្នា ដោយសារថា តាមរយៈការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* នេះ

---

សិទ្ធិបែបនេះជាពិសេសរួមមាន សិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ ...”។ មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏មានចែងនូវបញ្ញត្តិស្រដៀងគ្នានេះដែរ។ មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ “ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី”។ សិទ្ធិមនុស្សជាសារវន្តរបស់ជនជាប់ចោទដែលត្រូវបានជំនុំជម្រះក្តីដោយតុលាការឯករាជ្យ និងមិនលម្អៀងក៏ត្រូវបានទទួលផងដែរនៅក្នុងសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សសំខាន់ៗដទៃទៀតដែរ។ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សឆ្នាំ ១៩៤៨ ត្រង់មាត្រា ១០ ចែងថា៖ “មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាពេញលេញ សុំឲ្យតុលាការឯករាជ្យនិងមិនលម្អៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈនិងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ”។

[៣១] រដ្ឋធម្មនុញ្ញ មាត្រា ៣១។

ភាគីខ្លះនឹងបានទទួលព័ត៌មានដោយសម្ងាត់ (ហើយអាចនឹងទទួលបានឥទ្ធិពលទៀតផង) ដែលភាគីដទៃទៀតមិនបានទទួល។ ការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* បង្ហាញពីភាពលម្អៀង ឬយ៉ាងហោចណាស់ក៏ធ្វើឱ្យលេចចេញនូវភាពលម្អៀង ដែលរំលោភដល់សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការដែលមិនលម្អៀង។ នៅពេលការប្រាស្រ័យទាក់ទងការងារបានកើតឡើងរវាងអង្គជំនុំជម្រះសាលាដំបូង តាមរយៈតំណាង ឬអ្នកក្រោមបង្គាប់របស់ខ្លួន ជាមួយភាគីមួយដោយពុំបានជូនដំណឹងដល់ភាគីដទៃទៀតពីអ្វីដែលបានពិភាក្សាគ្នានោះ ជាធម្មតា ភាគីដទៃទៀតនឹងយល់ថា អាចនឹងមានការពិភាក្សាពីព័ត៌មានសំខាន់ៗ ឬអាចនឹងមានការសម្រេចអ្វីមួយដោយគ្មានការចូលរួមរបស់ភាគីទាំងនោះមិនខាន[៣២]។ ការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* ធ្វើឱ្យប៉ះពាល់ដោយការជឿទុកចិត្តពីភាគីនានានៅក្នុងកិច្ចដំណើរការនីតិវិធី នាំឱ្យមានការសង្ស័យ និងធ្វើឱ្យមានចំណាប់អារម្មណ៍ថា អង្គជំនុំជម្រះសាលាដំបូងកំពុងប្រព្រឹត្តចំពោះភាគីម្ខាងប្រសើរជាងភាគីម្ខាងទៀត។ ទង្វើបែបនេះគឺផ្ទុយទៅនឹងគោលការណ៍ដែលត្រូវបានគេទទួលស្គាល់ដែលថា ត្រូវ

---

[៣២] ឧទាហរណ៍ នាយកមជ្ឈមណ្ឌលក្រមសីលធម៌ចៅក្រម (Center for Judicial Ethics) នៃស្ថាប័នតុលាការអាមេរិកាំង (American Judicature Society) Cynthia Gray ពិភាក្សាលើរឿងក្តីមួយដែលចៅក្រមមួយរូបត្រូវបានចោទប្រកាន់ថាបានប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* ជាមួយមេធាវីដែលពាក់ព័ន្ធនឹងសំណុំរឿងរបស់ខ្លួន តែគាត់បានអះអាងថាជូនកាលមេធាវីទាំងនេះចូលមកក្នុងបន្ទប់ការិយាល័យរបស់គាត់ដើម្បីសួរសុខទុក្ខ នៅថ្ងៃដែលពួកគេមានវត្តមាននៅក្នុងតុលាការតែប៉ុណ្ណោះ និងបានបដិសេធថា ពួកគេពុំដែលបានពិភាក្សារឿងក្តីនានាដែលគាត់ជាអ្នកសម្រេចសេចក្តីទេ។ នាយករូបនេះបានអះអាងថា៖ "ភាពពុំត្រឹមត្រូវពិតប្រាកដនៅក្នុងរឿងក្តី Kennick តទល់នឹង គណៈកម្មការក្រមសីលធម៌តុលាការ នឹងត្រូវបានបង្ហាញមិនខាន ប្រសិនបើមានមេធាវីណាម្នាក់បានជួបជាមួយចៅក្រមនោះតែម្នាក់ឯងនៅក្នុងបន្ទប់ការងារ ទទួលស្គាល់ថា ពួកគេពិតជាបានប្រាស្រ័យទាក់ទងការងារជាមួយ *ភាគីតែម្ខាង* អំពីសំណុំរឿងដែលចៅក្រមនោះនឹងលើកយកមកពិចារណានៅកាលវិភាគរបស់ចៅក្រមនោះ។ ទោះបីពុំមានភស្តុតាងជាក់ស្តែងពីការប្រាស្រ័យទាក់ទងការងារជាមួយ *ភាគីតែម្ខាង* ក៏ដោយ ទោះជាយ៉ាងណាក្តី តុលាការកំពូលរដ្ឋកាលីហ្វ័រនីញ៉ាបានសន្និដ្ឋានថា ទម្លាប់អនុវត្តនៃការសួរសុខទុក្ខរបស់ចៅក្រមនោះជាមួយមេធាវីពីររូបដែលគាត់ពេញចិត្ត នៅថ្ងៃដែលពួកគេមានវត្តមានក្នុងតុលាការរបស់គាត់នោះ បាននាំឱ្យលេចឡើងនូវភាពមិនត្រឹមត្រូវ និយាយម្យ៉ាងទៀតគឺថា ការលេចឡើងនូវការប្រាស្រ័យទាក់ទងការងារជាមួយ *ភាគីតែម្ខាង* នោះឯង" Cynthia Gray, *The Ben J. Altheimer Symposium: Courtroom with a View: Perspectives on Judicial Independence: In Honor of Judge Richard Sheppard Arnold: Avoiding the Appearance of Impropriety: With Great Power Comes Great Responsibility*, 28 U. ARK. LITTLE ROCK L. REV. 63, 89 (2005)។

បង្ហាញឲ្យឃើញថា មានដំណើរការប្រកបដោយយុត្តិធម៌[៣៣]។ ទោះបីជានៅក្នុងករណីនេះ ភាពលម្អៀងអាចពុំមានពិតជាក់ស្តែងក៏ដោយ អ្វីដែលជាសំណួរនោះគឺថាតើ ភាពលម្អៀងនោះអាចយកជាមូលដ្ឋានសម្រាប់វាយតម្លៃថាតើគេអាចទទួលយក ឬអនុញ្ញាតឲ្យមានការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* ឬយ៉ាងណានោះទេ។ លទ្ធផលនៃការវាយតម្លៃនេះមិនអាចកំណត់ថាតើទង្វើនោះត្រូវបាន ឬមិនត្រូវបានហាមឃាត់នោះទេ។ ការណែនាំទម្លាប់អនុវត្តណាផ្សេងនឹងធ្វើឲ្យក្លាយជាទំនៀមសាកលដែលថា កំហុសលើអង្គច្បាប់កើតមានជាក់ស្តែង លុះត្រាតែលទ្ធផលនាំឲ្យមានបុរេនិច្ឆ័យពិតប្រាកដ។ ចំណុចនឹងប៉ះពាល់ដល់ដំណើរការយុត្តិធម៌។

២៤. ចៅក្រមមានកាតព្វកិច្ចក្នុងការមិនចូលរួមក្នុងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* និងមានកាតព្វកិច្ចរារាំងមិនឲ្យមន្ត្រីរបស់ខ្លួនចូលរួមការប្រាស្រ័យទាក់ទងការងារបែបនោះ[៣៤]។ គោលការណ៍ក្រមសីលធម៌ចៅក្រម Bangalore ឆ្នាំ ២០០២ ដែលត្រូវបានបង្កើតឡើងដើម្បីពង្រឹងគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជភាពនៃស្ថាប័នតុលាការឆ្នាំ ១៩៨៥ និងមានគោលបំណងឲ្យចៅក្រមនៅទូទាំងពិភពលោកយកទៅអនុវត្តនោះ[៣៥] ចែងថា "ចៅក្រមមិនត្រូវ

---

[៣៣] តាមប្រសាសន៍របស់ Lord Hewart C.J.៖ "យុត្តិធម៌មិនត្រឹមតែបង្កើតឲ្យមាននោះទេ តែគេត្រូវបង្ហាញឲ្យឃើញច្បាស់ដោយឥតសង្ស័យថាបានបង្កើតឲ្យមានដែរ" *រឿងក្តី R តទល់នឹង Sussex Justices, Ex parte McCarthy* [1924] 1 KB 256, [1923] All ER 233។

[៣៤] ចំពោះច្បាប់ដែលពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់ចៅក្រមក្នុងការមិនការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង សូមមើល* សំណើរបស់លោក អៀង សារី ស្នើឲ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយលោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E137/3; បណ្តឹងលើទីពីររបស់លោក អៀង សារី ប្តឹងសុំដឹតចិត្តចៅក្រម Marcel LEMONDE និងបណ្តឹងរួមគ្នាជាមួយមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធិ ប្តឹងសុំដឹតចិត្តចៅក្រម Marcel LEMONDE និងសំណើសុំឲ្យមានសវនាការជាសាធារណៈ, ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩, ១។

[៣៥] *សូមមើល* ក្រុមការងារស្តីពីក្រមសីលធម៌ចៅក្រម, បណ្តាញក្រុមប្រឹក្សាយុត្តិធម៌អឺរ៉ុប, Consiglio Superiore Della Magistratura, ទំព័រ ២៥។ គោលការណ៍ Bangalore ត្រូវបានពិនិត្យឡើងវិញ និងកែប្រែ អនុលោមទៅតាមការអធិប្បាយរបស់យុត្តាធិការក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងខំមិនឡមួយចំនួនធំ។ សម្រាប់ការពណ៌នាពីដំណើរការនេះ *សូមមើល* ក្រុមអធិបតេយ្យតុលាការ សេចក្តីអធិប្បាយលើគោលការណ៍ Bangalore នៃក្រមសីលធម៌ចៅក្រម, ខែ មីនា ឆ្នាំ ២០០៧ ទំព័រ ៩-១៨ *អាចរកបាននៅលើគេហទំព័រ៖* http://www.coe.int/t/dghl/cooperation/ccje/textes/BangalorePrinciplesComment.PDF។

អនុញ្ញាតដោយដឹងជាមុនឲ្យមន្ត្រីតុលាការ ឬមន្ត្រីដទៃទៀតដែលស្ថិតក្រោមឥទ្ធិពល ការណែនាំ ឬការគ្រប់គ្រងរបស់ខ្លួន ធ្វើការបែងចែកបុគ្គលនានាដែលពាក់ព័ន្ធនឹងរឿងក្ដីនៅចំពោះមុខចៅក្រមរូបនោះ ដោយសារមូលដ្ឋានមិនពាក់ព័ន្ធណាមួយនោះទេ”[៣៦]។ ស្រដៀងគ្នានេះដែរ ទោះបីពុំបានចែងឲ្យបានច្បាស់ក៏ដោយ តែប្រការ ៣២ នៃក្រមសីលធម៌ចៅក្រមកម្ពុជាចែងថា៖ “បច្ចុប្បន្ននេះចៅក្រមបំពេញកិច្ចការតុលាការផង និងកិច្ចការរដ្ឋបាលខ្លះផង។ ដូច្នេះកិច្ចការខ្លះត្រូវបំពេញដោយបុគ្គលិកតុលាការ ឬ អយ្យការក្រោមការត្រួតពិនិត្យ និងណែនាំពីចៅក្រម។ ក្នុងន័យនេះ ចៅក្រមត្រូវត្រួតពិនិត្យលើបុគ្គលិកតុលាការ ឬ អយ្យការទាំងនោះឲ្យបំពេញកិច្ចការដែលខ្លួនទទួលខុសត្រូវប្រកបដោយវិរិយភាព”។

២៥. កាតព្វកិច្ចរបស់ចៅក្រមក្នុងការធានាថា មន្ត្រីបុគ្គលិករបស់ចៅក្រមមិនរំលោភកាតព្វកិច្ចក្រមសីលធម៌របស់ចៅក្រម ជាការអនុវត្តទូទៅនៅក្នុងយុត្តាធិការតុលាការជាច្រើន។ ឧទាហរណ៍ វិធាន ២.៩ នៃក្រមគំរូនៃក្រមសីលធម៌ចៅក្រមរបស់គណៈមេធាវីអាមេរិកាំង ចែងថា៖ “ចៅក្រមមិនត្រូវផ្ដួចផ្ដើម អនុញ្ញាត ឬពិនិត្យពិចារណាលើការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង* ឬពិនិត្យពិចារណាការប្រាស្រ័យទាក់ទងការងារដទៃទៀតដែលចៅក្រមខ្លួនឯងបានធ្វើ ដោយពុំមានវត្តមានភាគីនានា ឬមេធាវីរបស់ពួកគេ ពាក់ព័ន្ធនឹងបញ្ហាដែលកំពុងដោះស្រាយ ឬដែលជិតសម្រេចនោះទេ ...។ ចៅក្រមត្រូវខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត រួមទាំងធ្វើការគ្រប់គ្រងឲ្យបានសមរម្យ ដើម្បីធានាថា បុគ្គលិកតុលាការ មន្ត្រីតុលាការ និងបុគ្គលដទៃទៀតដែលស្ថិតក្រោមការណែនាំ និងគ្រប់គ្រងរបស់ចៅក្រមរូបនោះ ពុំបានរំលោភបំពានលើវិធាននេះទេ”[៣៧]។

២៦. ចំពោះសំណុំរឿងយើងវិញ មិនត្រឹមតែមិនបានធានាថា មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានចៀសពីការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង*ប៉ុណ្ណោះទេ តែអង្គជំនុំ

---

[៣៦] គោលការណ៍ Bangalore, គោលការណ៍លេខ ៥, ចំណុច ៥.៤។

[៣៧] *អាចរកបាននៅលើគេហទំព័រ៖* http://www.americanbar.org/content/dam/aba/administrative/professional_responsibility/2010_mcjc_final.authcheckdam.pdf។ *សូមមើលផងដែរ* ក្រមគំរូនៃក្រមសីលធម៌ចៅក្រមរបស់គណៈមេធាវីអាមេរិកាំង វិធាន ២.៣(ក)-(ខ) វិធាន ១២.២(ក)។

ជម្រះសាលាដំបូងថែមទាំងបានអនុញ្ញាតយ៉ាងច្បាស់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើសារអេឡិចត្រូនិកទៅកាន់ភាគីមួយចំនួន ដោយជូនដំណឹងពីសាក្សី និងអ្នកជំនាញ ដែលអង្គជំនុំជម្រះនឹងកោះហៅ និងសាកសួរថា តើពួកគេមានបំណងចង់សាកសួរសំណួរដល់សាក្សីទាំងនេះឬទេ។ អង្គជំនុំជម្រះក៏បានធ្វើមិនដឹងមិនឮចំពោះករណីមួយទៀតរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន ក្នុងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង*[៣៨] ហើយអង្គជំនុំជម្រះខកខានមិនបានបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់បញ្ឈប់ទម្លាប់អនុវត្តបែបនោះទេ។ ហេតុនេះ អង្គជំនុំជម្រះបណ្តែតបណ្តោយដោយតុណ្ហីភាពឲ្យមានការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* និងបង្កើតជានីតិវិធីមួយ ដែលមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងអាចចូលរួមដោយសេរីទៅក្នុងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* ជាមួយភាគីណាមួយ នាពេលណាមួយ ពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗនៃការរៀបចំសវនាការ។

២៧. ការដែលមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីមួយចំនួនអំពីសាក្សីដែលអាចនឹងបង្ហាញខ្លួននៅក្នុងសវនាការបន្ទាប់នោះ បានផ្តល់ឲ្យភាគី *ដែលបានទទួលដំណឹង* នោះនូវអត្ថប្រយោជន៍ និងអាចនាំឲ្យភាគី *ដែលមិនបានទទួលដំណឹង* យល់ថា អង្គជំនុំជម្រះសាលាដំបូងបង្ហាញពីភាពលម្អៀងប្រឆាំងនឹងខ្លួន[៣៩]។ ដោយដឹងថា សាក្សីរូបណានឹងមានវត្តមាននាពេលសវនាការបន្ទាប់ អនុញ្ញាតឲ្យសាក្សីដែលបានដឹងដំណឹងនេះអាចរៀបចំខ្លួនជាមុនសម្រាប់តទល់ជាមួយសាក្សីទាំងនោះ។ ដោយសារមានសាក្សីខ្លះបានទទួលដំណឹងពីសាក្សីទាំងនេះមុនសាក្សីដទៃទៀតនោះ ពួកគេមានពេលវេលាច្រើនក្នុងការត្រៀមខ្លួនសម្រាប់តទល់ជាមួយសាក្សីទាំងនោះ ជាងភាគី *ដែលមិនបានទ*ទួលដំណឹង។ អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែខកខានមិនបានទទួលស្គាល់

---

[៣៨] *សូមមើលជើងទំព័រខាងលើ* លេខ ១៨។

[៣៩] ស្រដៀងគ្នានេះដែរ ការដែលមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានប្រាប់ភាគីមួយចំនួនពីពេលវេលាចាប់ផ្តើមសវនាការនោះ តែមិនបានជូនដំណឹងដល់ភាគីដទៃទៀតនោះ បានផ្តល់អត្ថប្រយោជន៍ដោយមិនយុត្តិធម៌ដល់ភាគី *ដែលបានទ*ទួលព័ត៌មាន និងអាចនាំឲ្យភាគី *ដែលមិនបានទ*ទួលព័ត៌មានយល់ថា អង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងប្រឆាំងនឹងខ្លួន។ ដោយដឹងថាសាក្សីរូបណានឹងមានវត្តមាននាពេលសវនាការបន្ទាប់ អនុញ្ញាតឲ្យសាក្សីដែលបានដឹងដំណឹងនេះ អាចរៀបចំខ្លួនជាមុនសម្រាប់តទល់ជាមួយសាក្សីទាំងនោះ។ ដោយសារមានសាក្សីខ្លះបានទទួលដំណឹងពីសាក្សីទាំងនេះមុនសាក្សីដទៃទៀតនោះ ពួកគេមានពេលវេលាច្រើនក្នុងការត្រៀមខ្លួនសម្រាប់តទល់ជាមួយសាក្សីទាំងនោះ ជាងភាគី *ដែលមិនបានទ*ទួលដំណឹង។

ពីមហន្តរាយដែលកើតឡើង ដោយសារការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង*របស់មន្ត្រីច្បាប់ជាន់ខ្ពស់ខ្លួនបានធ្វើ និងកំពុងបន្តធ្វើប៉ុណ្ណោះទេ តែអង្គជំនុំជម្រះបានបដិសេធមិនឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់ធ្វើការកែប្រែការប្រព្រឹត្តិដែលមិនអាចទទួលយកបាននោះទៀតផង។ ចំណុចនេះបានបង្ហាញច្បាស់នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ថា៖ អង្គជំនុំជម្រះមិនត្រឹមតែបណ្តែតបណ្តោយឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងធ្វើសកម្មភាពបែបនោះទេ តែបានបង្ហាញថា សំណើនេះជាចេតនាព្យាយាមអូសបន្លាយកិច្ចដំណើរការនីតិវិធី និងមិនបន្ទាន់ទេ[៤០]។ និយាយតាមបែបផ្សេងវិញគឺថា អង្គជំនុំជម្រះសាលាដំបូងមិនបានយល់ពីចំណុចសំខាន់ ឬមិនអើពើដោយគ្មានមេត្តា។

២៨. អង្គជំនុំជម្រះសាលាដំបូងគួរបង្គាប់ឱ្យក្រឡាបញ្ជីរបស់ខ្លួនឆ្លើយតបទៅនឹងបញ្ហានានាដែលពាក់ព័ន្ធនឹងសាក្សី។ វិធាន ៨៤(២) ចែងថា៖ "ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវកោះហៅជាបន្ទាន់នូវសាក្សី និងអ្នកជំនាញដែលបានទទួលការយល់ព្រមរួចហើយ។ សាក្សី និងអ្នកជំនាញនោះត្រូវឆ្លើយតបទៅនឹងការកោះហៅ និងមកបង្ហាញខ្លួនក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងស្របតាមវិធានផ្ទៃក្នុង"[៤១]។ ខុសពីមន្ត្រីច្បាប់ ក្រឡាបញ្ជីតម្រូវឱ្យមានការតែងតាំងដោយក្រសួងយុត្តិធម៌[៤២]។ ការតែងតាំងនេះបង្ហាញពីការត្រួតពិនិត្យរបស់ក្រសួងយុត្តិធម៌ចំពោះលក្ខណៈសម្បត្តិមួយចំនួន និងការស្បថចូលកាន់តំណែងទៀតផង។ ដំណើរការនេះនឹងបញ្ជាក់ទៅក្រឡាបញ្ជីឱ្យបំពេញការងាររបស់ខ្លួនដោយអនុលោមទៅតាមកាតព្វកិច្ចក្រមសីលធម៌

---

[៤០] *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់, ទំព័រ ២។

[៤១] គូសបញ្ជាក់បន្ថែម។ បន្ថែមទៅទៀត ជាជាងអនុញ្ញាតឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនជូនដំណឹងទៅភាគីមួយចំនួន" ដែលបានជ្រើសរើស" អំពីការចាប់ផ្តើមការជំនុំជម្រះក្តី អង្គជំនុំជម្រះសាលាដំបូងគួរចេញបញ្ជាឱ្យក្រឡាបញ្ជីរបស់ខ្លួន ទំនាក់ទំនងពីការផ្តើមការជំនុំជម្រះក្តី ជាមួយភាគីនានា អនុលោមតាមវិធាន ៨០(៦) ដែលថា៖ "ភាគីត្រូវតែបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទនៃសវនាការ *ដោយក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង*ឱ្យបានឆាប់ដែលអាចធ្វើទៅបាន។ ការជូនដំណឹងនេះត្រូវចាត់ទុកជាការបង្គាប់ឱ្យចូលខ្លួនដែលមានសុពលភាព" (គូសបញ្ជាក់បន្ថែម)។

[៤២] វិធាន ១៦*ស្ទួន* ចែងថា៖ "ដើម្បីអនុវត្តមុខងាររបស់ខ្លួននៅក្នុង អ.វ.ត.ក ដូចដែលបានចែងក្នុងវិធានផ្ទៃក្នុងនេះ មន្ត្រី អ.វ.ត.ក ដែលត្រូវបំពេញមុខងារជាក្រឡាបញ្ជី ត្រូវទទួលនីតិសម្បទាពីក្រសួងយុត្តិធម៌។ ដើម្បីបំពេញតាមតំរូវការនេះ ការិយាល័យរដ្ឋបាលត្រូវបញ្ជូនបញ្ជីឈ្មោះក្រឡាបញ្ជី ជាបន្ទាន់ទៅក្រសួងយុត្តិធម៌ដើម្បីផ្តល់នីតិសម្បទា"។

របស់ចៅក្រម និងក្រមសីលធម៌របស់ខ្លួនផងដែរ។

២៩. ការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន ឱ្យចូលរួមក្នុងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* គឺជាការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ។ ការរំលោភសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីដែលមិនលម្អៀង និងមានការប្រព្រឹត្តឱ្យបានស្មើគ្នាទៅនឹងជនជាប់ចោទដទៃទៀតនោះ ជាការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ។ សកម្មភាពរបស់អង្គជំនុំជម្រះសាលាដំបូងផ្ដល់ផលប៉ះពាល់ដោយផ្ទាល់ក្នុងការជ្រៀតជ្រែកទៅសិទ្ធិរបស់លោក អៀង សារី។

**ខ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ និងបានជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ដោយណែនាំមិនឱ្យភាគីដាក់ចម្លើយតបទៅនឹងសំណើនេះ**

៣០. ភាគីមានសិទ្ធិជាសារវន្តក្នុងការទទួលបានសវនាការប្រកបដោយយុត្តិធម៌ ដើម្បីឆ្លើយតបទៅនឹងសំណើនានាដែលបានដាក់ដោយភាគី។ សិទ្ធិក្នុងការឆ្លើយតបនេះជាធាតុដ៏សំខាន់ដើម្បីធ្វើជាកំណត់ហេតុ និងដោយសារថា "ភស្តុតាង ឬទឡ្ហីករណ៍ដែលមិនត្រូវបានជំទាស់ មានលក្ខណៈលេចធ្លោជាង អាចត្រូវបានអ្នកសម្រេចសេចក្ដីលើកយកមកនិយាយជាង និងបើតាមដំណើរការផ្លូវចិត្ត វាអាចមានទម្ងន់ជាងក្នុងការសម្រេចសេចក្ដីសន្និដ្ឋានស្ថាពរ"[៤៣]។ សិទ្ធិក្នុងការឆ្លើយតបកើតចេញពីសិទ្ធិទទួលបានសមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្ដី និងកិច្ចដំណើរការនីតិវិធីស្ទួរតទល់គ្នា។ គោលការណ៍សមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្ដី កំណត់ថា "សហមេធាវីការពារក្ដី និងសហព្រះរាជអាជ្ញា ត្រូវមានសមភាពក្នុងនីតិវិធី ដើម្បីធានាថា ការអនុវត្តកិច្ចដំណើរការនីតិវិធីតុលាការមានភាពយុត្តិធម៌"[៤៤]។ គោលការណ៍នេះជាគោលការណ៍សារវន្ត

[៤៣] John R. Allison, *Combinations of Decision-Making Functions, ex Parte Communications, and Related Biasing Influences: A Process-Value Analysis*, 1993 UTAH L. REV. 1135, 1197 (1993)។

[៤៤] *រឿងក្ដី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"*, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ, សេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម, ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារលេខ E90, កថាខណ្ឌ ៤។

ចំពោះលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ រួមទាំង ICCPR[៨៥] ដែល អ.វ.ត.ក ត្រូវគោរពតាម ដោយអនុលោមទៅតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ១៣(១) នៃកិច្ចព្រមព្រៀង។ គោលការណ៍នេះក៏ត្រូវបានតម្រូវផងដែរដោយវិធាន ២១ (១)(ក) ដែលចែងថា៖ "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ..."។

៣១. អង្គបុរេជំនុំជម្រះធ្លាប់បានប្រឈមមុខនឹងបញ្ហាថា តើភាគីមានសិទ្ធិឆ្លើយតបឬទេ បន្ទាប់ពី ក.ស.ច.ស បដិសេធមិនទទួលយកចម្លើយតបរបស់មេធាវីការពារក្តី ចំពោះដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា សិទ្ធិក្នុងការឆ្លើយតបមានទំនាក់ទំនងទៅនឹងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្តី និងបានសន្និដ្ឋានថា ក.ស.ច.ស បានរំលោភលើសិទ្ធិនេះ ដោយទទួលយកសារណាដែលបានដាក់ដោយ ក.ស.ព ខណៈដែលខ្លួនបានច្រានចោលសិទ្ធិក្នុងការឆ្លើយតបរបស់មេធាវីការពារក្តី។ អង្គបុរេជំនុំជម្រះបានច្រានចោលសេចក្តីសម្រេចរបស់ ក.ស.ច.ស និងបានបង្គាប់ឱ្យ ក.ស.ច.ស បញ្ចូលចម្លើយតបនោះទៅក្នុងសំណុំរឿង[៨៦]។ អង្គបុរេជំនុំជម្រះបានអះអាងថា "វាជាការដែលអាចយល់បានយ៉ាងប្រាកដថា ជនត្រូវ

---

[៨៥] បើតាមវិធាន ១៤(១) ចែងថា៖ "ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី ..."។ *សូមមើលផងដែរ រឿងក្តី Fei តទល់នឹង ប្រទេសកូឡុំប៊ី* ឯកសារទំនាក់ទំនងលេខ 514/1992, U.N. Doc. CCPR/C/53/D/514/1992 (ឆ្នាំ ១៩៩៥) កថាខណ្ឌ៨.៤៖ "ទស្សនាទាននៃ "ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌" នៅក្នុងអត្ថន័យនៃមាត្រា ១៤ កថាខណ្ឌ ១ ... ក៏មានបញ្ចូលធាតុផ្សំផងទៀតដែរ។ ក្នុងចំណោមនោះ គណៈកម្មាធិការមានឱកាសក្នុងការលើកឡើងនូវ ... គឺការគោរពដល់គោលការណ៍សមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្តី កិច្ចដំណើរការនីតិវិធីស្ងួរដេញដោល និងកិច្ចដំណើរការនីតិវិធីឆាប់រហ័ស"។

[៨៦] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោម **បណ្តឹងសាទុក្ខរបស់លោកអៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធ**

ចោទអាចចង់ធ្វើសេចក្តីសន្និដ្ឋាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា នៅក្នុងដីកាសន្និដ្ឋានស្ថាពរដែលត្រូវបានសហចៅក្រមស៊ើបអង្កេតយកទៅពិចារណាមុនពេលចេញដីកាដំណោះស្រាយ ដែលសម្រេចថាតើជនត្រូវចោទប្រឈមនឹងការជំនុំជម្រះក្តីដែរឬទេ និងត្រូវប្រឈមនឹងបទចោទប្រកាន់អ្វីខ្លះ។ លើសពីនេះទៀត មុនពេលដំណាក់កាលសំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក នេះ សហចៅក្រមស៊ើបអង្កេតគ្រាន់តែអាចទទួលប្រយោជន៍ពីការទទួលបានសេចក្តីសន្និដ្ឋានពីសហព្រះរាជអាជ្ញាផង ពីសហមេធាវីការពារក្តីផង"[៤៧]។

៣២. សិទ្ធិក្នុងការឆ្លើយតបទៅនឹងសំណើដែលបានដាក់ដោយភាគីដទៃទៀតក៏មានទំនាក់ទំនងផងដែរទៅនឹងសិទ្ធិទទួលបានកិច្ចដំណើរការនីតិវិធីស្មើរតទល់គ្នា ដែលកំណត់ដោយវិធាន ២១(១)(ក)[៤៨]។ សិទ្ធិទទួលបានកិច្ចដំណើរការនីតិវិធីស្មើរតទល់គ្នា "មានន័យថា ជាគោលការណ៍ វាជាឱកាសសម្រាប់ឲ្យភាគីក្នុងរឿងក្តីព្រហ្មទណ្ឌក្តី ឬរដ្ឋប្បវេណីក្តី បានដឹង និងបានបញ្ចេញយោបល់ទៅភស្តុតាងទាំងអស់ដែលបានដាក់ ឬសេចក្តីសង្កេតនានាដែលបានដាក់ ទោះបីត្រូវបានដាក់ដោយមន្ត្រីជាតិដែលប្រកបអាជីពផ្នែកច្បាប់ដោយឯករាជ្យក៏ដោយ ដែលមានបំណងមានឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់តុលាការ"[៤៩]។ បើតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtHR") គឺថា៖

> មានវិធីសាស្ត្រជាច្រើនដែលអាចចាត់ទុកថា ច្បាប់ជាតិអាចស្របទៅនឹងលក្ខខណ្ឌតម្រូវនេះ។ ទោះជាយ៉ាងណាក្តី ទោះបីគេជ្រើសរើសយកវិធីសាស្ត្រណាក៏ដោយ ក៏គេគួរតែធានាថា ភាគីដទៃទៀតនឹងដឹងថា សេចក្តីសង្កេតនានាត្រូវបានដាក់ *ហើយពួកគេនឹងទទួលបាននូវឱកាសពិតប្រាកដមួយក្នុងការបញ្ចេញយោបល់ទៅលើសេចក្តីសង្កេតទាំង*

---

តាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ D390/1/2/4។

[៤៧] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១៨។

[៤៨] វិធាន ២១(១០(ក) ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

[៤៩] *រឿងក្តី Lobo Machado តទល់នឹង ប្រទេស ព័រទុយហ្គាល់*, Eur. Ct. H. R. App. no. 15764/89 (ឆ្នាំ ១៩៩៦) កថាខណ្ឌ ៣១។

*នោះ*[៥០] ។

៣៣. នៅក្នុងសំណុំរឿងនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់មិនឲ្យភាគីនានាធ្វើការឆ្លើយតបទៅនឹងសំណើនេះ ដោយរំលោភទៅលើសិទ្ធិរបស់លោក អៀង សារី និងសិទ្ធិរបស់ភាគីដទៃទៀតក្នុងការទទួលបានសមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្តី និងកិច្ចដំណើរការនីតិវិធីស្ងួរតទល់គ្នា។ ការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនឲ្យផ្តល់ព័ត៌មានស្តីពីបញ្ហាសំខាន់ៗនៃការរៀបចំសវនាការតែចំពោះភាគីជាក់លាក់មួយចំនួននោះ មានសក្តានុពលមានឥទ្ធិពលអវិជ្ជមានទៅលើភាគីនានាដែលគាត់មិនបានជូនដំណឹង។

៣៤. ការរំលោភបំពានរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសិទ្ធិរបស់ភាគីក្នុងការទទួលបានសមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្តី បង្កើតជាការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ។ សកម្មភាពរបស់អង្គជំនុំជម្រះសាលាដំបូងមានឥទ្ធិពលដោយផ្ទាល់ដោយជ្រៀតជ្រែកទៅលើសិទ្ធិរបស់ភាគី។ ទោះបីនៅក្នុងករណីនេះ មេធាវីការពារក្តី ដែលជាភាគីដាក់សំណើ នឹងពុំមានសិទ្ធិក្នុងការឆ្លើយតបក៏ដោយ ក៏លោក អៀង សារី ត្រូវទទួលរងគ្រោះដោយ

---

[៥០] *រឿងក្តី* Öcalan *តទល់នឹង ប្រទេសទួរគី*, Eur. Ct. H.R., App. no. 46221/99 (ឆ្នាំ ២០០៥), កថាខណ្ឌ ១៤៦ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ រឿងក្តី* Brandstetter *តទល់នឹង ប្រទេសអូទ្រីស្ត*, Eur. Ct. H.R. App. no. 11170/84; 12876/87; 13468/87 (ឆ្នាំ ១៩៩១), កថាខណ្ឌ ៦៧។ ស្រដៀងគ្នានេះដែរ តុលាការ ECtHR បានសន្និដ្ឋានថា សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ត្រូវបានរំលោភ នៅពេលដែលអ្នកដាក់ពាក្យសុំត្រូវបានបដិសេធមិនផ្តល់ឱកាសក្នុងការឆ្លើយតបទៅនឹងសារណាជាលាយលក្ខណ៍អក្សរដែលបានដាក់ដោយមេធាវីតំណាងរដ្ឋ។ នៅក្នុង *រឿងក្តី Ruiz-Mateos តទល់នឹង ប្រទេសអេស្ប៉ាញ* អ្នកដាក់ពាក្យសុំបានចោទប្រកាន់ថា មានការរំលោភលើគោលការណ៍សមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្តី ដោយសំអាងថា មេធាវីតំណាងរដ្ឋាភិបាលអេស្ប៉ាញ ដែលជាគូវិវាទនៅក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណី អាចដាក់ជូនតុលាការធម្មនុញ្ញបាននូវសេចក្តីសង្កេតជាលាយលក្ខណ៍អក្សរ ទៅលើភាពស្របច្បាប់នៃលក្ខន្តិកៈមួយ ផ្ទុយទៅវិញអ្នកដាក់ពាក្យសុំទាំងនោះមិនត្រូវបានអនុញ្ញាតឲ្យដាក់សារណាជាលាយលក្ខណ៍អក្សរទេ ដោយពួកគេពុំមាន*លក្ខណៈសម្បត្តិតាមផ្លូវច្បាប់ (locus standi)*។ តុលាការនេះបានសម្រេចថា "តាមវិធាន ជនគ្រប់រូបត្រូវបានធានាក្នុងការអាចទៅពិនិត្យដោយសេរីចំពោះសេចក្តីសង្កេតរបស់អ្នកចូលរួមដទៃទៀត នៅក្នុងកិច្ចដំណើរការនីតិវិធីនេះ និងមានឱកាសពិតប្រាកដក្នុងការបញ្ចេញយោបល់ទៅលើសេចក្តីសង្កេតទាំងនោះ"។ *រឿងក្តី Ruiz-Mateos តទល់នឹង ប្រទេសអេស្ប៉ាញ*, 16 Eur. H. R. Rep. 505, App. No. 12952/87 (ឆ្នាំ ១៩៩៣) កថាខណ្ឌ ៦៣។

ការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងមិនឲ្យធ្វើការឆ្លើយតបនេះដែរ។ ទីមួយ អង្គជំនុំជម្រះសាលាដំបូងមានប្រវត្តិបដិសេធចោលសិទ្ធិនេះរបស់ភាគី[៥១]។ ក្នុងឱកាសផ្សេងទៀត មេធាវីការពារក្តីត្រូវបានហាមឃាត់ដោយអង្គជំនុំជម្រះសាលាដំបូងមិនឲ្យអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងសារណាដែលបានដាក់ដោយភាគីដទៃទៀត ដែលប៉ះពាល់ដល់លោក អៀង សារី ដោយសារសិទ្ធិរបស់គាត់ក្នុងការទទួលបានសមភាពនៃមធ្យោបាយរវាងគូភាគីក្នុងការតទល់ក្តី និងកិច្ចដំណើរការនីតិវិធីស្ទូរតទល់គ្នានោះ ត្រូវបានរំលោភ ហើយគាត់ត្រូវបានរារាំងមិនឲ្យចុះក្នុងកំណត់ហេតុទៀត។ ទីពីរ ជាពិសេសបើពិចារណាទៅលើជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទិននឹងការទទួលបានព័ត៌មានពីបញ្ហាទាំងនេះ វាហាក់ដូចជាថា ភាគីដទៃទៀតអាចគាំទ្រដល់សំណើនេះ តែពួកគេត្រូវបានហាមឃាត់មិនឲ្យធ្វើការឆ្លើយតប។

**គ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គច្បាប់ និងបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះយ៉ាងពិតប្រាកដ ដោយខកខានពុំបានចេញសេចក្តីសម្រេចដោយមានសំអាងហេតុទៅលើសំណើនោះ**

៣៥. លោក អៀង សារី មានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ ដោយត្រូវទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ។ យើងចាំបាច់ត្រូវមានសេចក្តីសម្រេចដែលមានសំអាងហេតុ ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព និងរក្សាសិទ្ធិរបស់ជនជាប់ចោទក្នុងការប្តឹងសាទុក្ខ។ គួរឲ្យសោកស្តាយ អង្គជំនុំជម្រះសាលាដំបូងមានទម្លាប់ចេញសេចក្តីសម្រេចរបស់ខ្លួននៅក្នុងទម្រង់ជាអនុស្សរណៈដោយមិនមានសំអាងហេតុ[៥២]។

---

[៥១] *សូមមើលជើងទំព័រខាងលើ* លេខ ១៥។

[៥២] ជាឧទាហរណ៍ មេធាវីការពារក្តីបានដាក់សំណើមួយទៅអង្គជំនុំជម្រះសាលាដំបូងឲ្យផ្អាកកិច្ចដំណើរការនីតិវិធី រហូតដល់មានសេចក្តីសម្រេចស្ថាពរ ចំពោះថាតើ អ.វ.ត.ក អាចអនុវត្តយុត្តាធិការរបស់ខ្លួនលើលោក អៀង សារី ដែរឬយ៉ាងណា ឬថាតើ អ.វ.ត.ក ត្រូវបានរារាំងដោយសារតែព្រះរាជទានលើកលែងទោស និងអនុគ្រោះទោសរបស់គាត់ និងបញ្ហានៃគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ *(ne bis in idem)*។ ដោយពុំទទួលបានការឆ្លើយតប និងជិតដល់ពេលសវនាការចាប់ផ្តើម មេធាវីការពារក្តីបានផ្ញើរលិខិតមួយទៅមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង។ នៅក្នុងអនុស្សរណៈ មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ៖ "ខណៈដែលអង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តី**បណ្តឹងសាទុក្ខរបស់លោកអៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់លោក អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធ**

៣៦. ពាក់ព័ន្ធនឹងសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបាននូវកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាពនោះ វិធាន ២១(១) តម្រូវថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព..."។ តម្លាភាពរួមមានការដឹងអំពីការធ្វើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ និងហេតុផលចំពោះសេចក្តីសម្រេចទាំងនោះ។ តាមរយៈការចេញសេចក្តីសម្រេចដោយមិនមានសំអាងហេតុ អង្គជំនុំជម្រះលាក់បាំងហេតុផល

---

សម្រេចលើអញ្ញត្រកម្មរបស់ក្រុមមេធាវីរបស់ អៀង សារី ទាក់ទិននឹងការលើកលែងទោស និងគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ កាលពីថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ (E51/15) នោះ សំណើរបស់ក្រុមមេធាវី អៀង សារី ស្នើសុំពន្យារការចាប់ផ្តើមសវនាការរហូតដល់មានសេចក្តីសម្រេចចុងក្រោយលើអញ្ញត្រកម្មនេះ (E135) កំពុងរង់ចាំការសម្រេច។ រហូតដល់ពេលនេះ អង្គជំនុំជម្រះបានបានផ្តល់អាទិភាព និងចេញសេចក្តីសម្រេចលើអញ្ញត្រកម្មទាំងអស់ជាប់ពាក់ព័ន្ធនឹងការរៀបចំសវនាការ ហើយអង្គជំនុំជម្រះបានយល់ឃើញថា សេចក្តីសម្រេចលើអញ្ញត្រកម្មដែលនៅសេសសល់មួយចំនួន តូចនោះ គឺមិនមែនជាឧបសគ្គដល់ការចាប់ផ្តើមសវនាការលើអង្គសេចក្តីនៅក្នុងសំណុំរឿង ០០២ នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឡើយ។ អង្គជំនុំជម្រះមិនមែនបំណងពន្យារដំណើរការនីតិវិធី ក្នុងករណីដែលសេចក្តីសម្រេចណាមួយលើអញ្ញត្រកម្ម ត្រូវបានប្តឹងឧទ្ធរណ៍នៅអង្គជំនុំជម្រះតុលាការកំពូលឡើយ។ *នេះគឺជាការឆ្លើយតបផ្លូវការរបស់អង្គជំនុំជម្រះចំពោះលិខិតរបស់ក្រុមមេធាវី អៀង សារី ជូនមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទាក់ទិននឹងព័ត៌មានអំពីអញ្ញត្រកម្មដែលនៅសេសសល់*"។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E141 ទំព័រ ៦ (សេចក្តីបញ្ជាក់បន្ថែម)។ បន្ទាប់ពីមេធាវីការពារក្តីបានសួរសំណួរនៅកិច្ចប្រជុំរៀបចំសវនាការមិនផ្លូវការក្រោយមកទៀត ថាតើសេចក្តីសម្រេចដែលមានសំអាងហេតុជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូង នឹងចេញក្នុងពេលឆាប់ៗនេះ ឬយ៉ាងណានោះ នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញនូវអនុស្សរណៈមួយ ដែលបញ្ជាក់ថា "អនុស្សរណៈនេះបញ្ជាក់ថា ឯកសារ E141 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ គឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើខាងលើ ដែលបានលើកបញ្ហានានាពាក់ព័ន្ធនឹងការរៀបចំសវនាការនាពេលបច្ចុប្បន្ន"។ សេចក្តីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើដែលនៅសេសសល់មុនសវនាការ (ឯកសារ E20, E132, E134, E135, E124/8, E124/9, E124110, E136 និង E139) និងការណែនាំបន្ថែមទៀតទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E145 ទំព័រ១។

របស់ខ្លួន ដោយមិនបានបញ្ជាក់ប្រាប់ដល់លោក អៀង សារី ភាគីទាំងអស់ និងសាធារណៈជនឱ្យដឹងអំពីថាតើអង្គជំនុំជម្រះឈានទៅដល់ការធ្វើសេចក្តីសម្រេចរបស់ខ្លួនបែបណាឡើយ។

៣៧. សិទ្ធិក្នុងការទទួលបានសេចក្តីសម្រេចដោយមានសំអាងហេតុ ត្រូវបានផ្សារភ្ជាប់ទៅនឹងសិទ្ធិក្នុងការទទួលបានការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។ សិទ្ធិក្នុងការទទួលបានការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខមានចែងនៅក្នុងមាត្រា ១៤(៥) នៃ ICCPR[៥៣] ដែលត្រូវតែគោរព អនុលោមតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ។ ដូចដែលអង្គបុរេជំនុំជម្រះបានយល់ឃើញ ៖ "ភាគីមានសិទ្ធិជាមូលដ្ឋានដើម្បីទទួលបានដំណឹងអំពីហេតុផលនៃសេចក្តីសម្រេចណាមួយ។ ប្រការនេះអនុញ្ញាតឱ្យភាគីបានដឹងអំពីមូលដ្ឋាននៃសេចក្តីសម្រេចនីមួយៗ ដែលធ្វើឱ្យភាគីរងគ្រោះស្ថិតក្នុងស្ថានភាពមួយដែលអាចកំណត់បានថាតើនឹងដាក់ប្តឹងឧទ្ធរណ៍ដែរឬយ៉ាងណា និងប្តឹងលើមូលដ្ឋានអ្វី"[៥៤]។

៣៨. ទោះបីជាសិទ្ធិក្នុងការទទួលបានសាលក្រមដោយមានសំអាងហេតុ មានចែងយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុង[៥៥] ហើយយុត្តិសាស្ត្រអន្តរជាតិតែងតែពិភាក្សាអំពីសិទ្ធិក្នុងការទទួលបានសេចក្តីសម្រេចដោយមានសំអាងហេតុនៅក្នុងបរិបទដែលគ្មានសាលក្រមដែលមានសំអាងហេតុ ក៏

---

[៥៣] មាត្រា ១៤(៥) ចែងថា "ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាប់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របតាមច្បាប់"។

[៥៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D365/2/10។ ប្រការ ៣០ នៃក្រមសីលធម៌ចៅក្រមក៏បានគាំទ្រសេចក្តីសន្និដ្ឋានដែលថា រាល់សេចក្តីសម្រេចរបស់តុលាការទាំងអស់គួរតែមានសំអាងហេតុ។ ប្រការនេះចែងថា៖ "ប្រការ ៣០ - អាទិភាពនៃមូលដ្ឋាន ឬសំអាងហេតុនៃសេចក្តីសម្រេច៖ ការរៀបចំមូលដ្ឋាន ឬសំអាងហេតុនៃសេចក្តីសម្រេច គឺជាដំណើរការលំបាក និងប្រើប្រាស់ពេលវេលាច្រើន។ ក្នុងន័យនេះ ចៅក្រមគប្បីមានពេលវេលាគ្រប់គ្រាន់ដើម្បីស្រាវជ្រាវពិភាក្សា និងសរសេរមូលដ្ឋាន ឬសំអាងហេតុនៃសេចក្តីសម្រេចនោះ។ ប៉ុន្តែ ចៅក្រមមិនត្រូវអូសបន្លាយពេលវេលានេះរហូតដល់បាត់បង់យុត្តិធម៌ឡើយ។

[៥៥] វិធាន១០១(៤) និង (៥) ចែងថា៖ " ៤. ផ្នែកសំអាងហេតុនៅក្នុងសាលក្រម ត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សរដែលបានធ្វើឡើងដោយភាគីទាំងអស់។ ៥. ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបញ្ជាក់ពីបទល្មើសនីមួយៗដែលប្រព្រឹត្តដោយជនជាប់ចោទ ច្បាប់ជាធរមាន ការផ្តន្ទាទោស និង សំណង។

អង្គបុរេជំនុំជម្រះ ដោយពិចារណាទៅលើវិធានផ្ទៃក្នុង[៥៦] លក្ខន្តិកៈរបស់តុលាការ ICTY[៥៧] វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY[៥៨] យុត្តិសាស្ត្ររបស់តុលាការ ICTY[៥៩] និង រឿងក្តី *Taxquet តទល់នឹង ប្រទេសបែលហ្ស៊ិក* របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR)[៦០]

---

[៥៦] អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា "ចំណុចទីមួយ ដើម្បីឱ្យសិទ្ធិប្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អនុលោមតាមវិធាន ៧៤(៣)(ខ) អនុវត្តបានពេញលេញ ជនត្រូវចោទត្រូវដឹងមូលហេតុដែលសហចៅក្រមស៊ើបអង្កេតបដិសេធសំណើរបស់ខ្លួន។ ករណីនេះតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតផ្តល់សំអាងហេតុលើសេចក្តីសម្រេចបដិសេធរបស់ខ្លួន ឱ្យបានលម្អិតគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីមូលដ្ឋាននៃសេចក្តីសម្រេចបដិសេធរបស់ខ្លួន។ ការធ្វើដូច្នេះ ដាក់ជនត្រូវចោទក្នុងស្ថានភាពមួយអាចឱ្យគេ សម្រេចថាតើត្រូវប្តឹងឧទ្ធរណ៍ដែរឬទេ ហើយត្រូវប្តឹងប្រឆាំងនឹងសំអាងហេតុចំណុចមួយណា និងអាចឱ្យគេរៀបចំសេចក្តី សន្និដ្ឋានឱ្យបានសមស្រប ដើម្បីជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍។ ចំណុចទីពីរ វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង ទាមទារឱ្យ អង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេច "ដោយមានសំអាងហេតុ" លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការអនុវត្តឆន្ទានុសិទ្ធិរបស់ សហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។ វិធានផ្ទៃក្នុងមិនអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះ តម្កល់ទុកការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតដែលបានបដិសេធសំណើឡើយ ប្រសិនបើខ្លួនមិនដឹងហេតុផល ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើនោះ"។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D353/2/3 កថាខណ្ឌ ២៣។

[៥៧] មាត្រា ២៣(២) នៃលក្ខន្តិកៈតុលាការ ICTY ចែងថា៖ "សាលក្រមត្រូវសម្រេចដោយសម្លេងភាគច្រើននៃចៅក្រមរបស់សភាជំនុំជម្រះ និងត្រូវថ្លែងដោយសភាចៅក្រមជំនុំជម្រះជាសាធារណៈ។ សាលក្រមត្រូវបញ្ជាក់ពីហេតុផលជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់បន្ថែមនូវទស្សនៈផ្ទុយ ឬខ្វែងគ្នា"។

[៥៨] វិធាន ៩៨ ស្ទួនពីរ (គ) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY ចែងថា ៖ "សាលក្រមត្រូវសម្រេចដោយសម្លេងភាគច្រើននៃចៅក្រម។ សាលក្រមត្រូវបញ្ជាក់ ឬអមមកជាមួយនូវហេតុផលជាលាយលក្ខណ៍អក្សរឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដែលត្រូវភ្ជាប់បន្ថែមនូវទស្សនៈផ្ទុយ ឬខ្វែងគ្នា"។

[៥៩] អង្គជំនុំជម្រះសាលាដំបូងខកខានពុំបានផ្តល់នូវឈ្មោះ ឬលេខនៃរឿងក្តីនៃសាលដីការបស់តុលាការ ICTY ដែលខ្លួនបានធ្វើការវិភាគ និងបានដកស្រង់។

[៦០] នៅក្នុងរឿងក្តី Taxquet ទល់នឹង បែលហ្ស៊ិក តុលាការសិទ្ធិមនុស្សអឺរ៉ុបបានពិចារណារឿងក្តីមួយដែលដើមបណ្តឹងត្រូវបានផ្តន្ទាទោសពីបទមនុស្សឃាត និងបទមនុស្សឃាតដោយគិតទុកជាមុនដោយតុលាការ Liege Assize ដោយមានសមាសភាពក្រុមប្រឹក្សាវិនិច្ឆ័យ (jury)។ ច្បាប់ប្រទេសប៊ែលហ្ស៊ិក មិនតម្រូវឱ្យតុលាការ Assize ឬក្រុមប្រឹក្សាវិនិច្ឆ័យ ផ្តល់សំអាងហេតុលើសាលក្រមឡើយ ហើយក្រុមប្រឹក្សាវិនិច្ឆ័យ ព្រមទាំងតុលាការ Assize នេះ មិនបានផ្តល់សំអាងហេតុក្នុងសាលក្រមនេះដែរ។ ដើមបណ្តឹងបានប្តឹងសាទុក្ខទៅតុលាការកំពូល ប៉ុន្តែបណ្តឹងសាទុក្ខរបស់គាត់ត្រូវបានបដិសេធ។ គាត់បានតវ៉ាទៅតុលាការសិទ្ធិមនុស្សអឺរ៉ុបថា សិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (មាត្រា ៦(១) នៃ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិ

**បណ្តឹងសាទុក្ខរបស់លោកអៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធ**

ព្រមទាំងគោលការណ៍ណែនាំពីគណៈកម្មការសិទ្ធិមនុស្ស[៦១] បានសន្និដ្ឋានថា សិទ្ធិនោះអនុវត្តចំពោះសេចក្តីសម្រេចផ្សេងៗទៀតផងដែរ៖

> ទោះបីជាយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងរបស់តុលាការ ICTY មានភាពពាក់ព័ន្ធទៅនឹងសាលក្រមលើពិរុទ្ធភាពក៏ដោយ ក៏ការយោងទៅលើយុត្តិសាស្ត្រទាំងនេះ មានភាពពាក់ព័ន្ធទៅនឹងបរិបទមុនអង្គសេចក្តីនៅ អ.វ.ត.ក នេះដែរ។ ទាំងភាគីដែលសំណើរបស់ខ្លួនត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះត្រូវដឹងអំពីមូលហេតុនៃការបដិសេធនោះឱ្យបានលម្អិតគ្រប់គ្រាន់ ដើម្បីឱ្យដើមបណ្តឹងឧទ្ធរណ៍សម្រេចបានថា តើត្រូវប្តឹងឧទ្ធរណ៍ឬទេ ហើយបើត្រូវប្តឹង តើបណ្តឹងឧទ្ធរណ៍

---

មនុស្ស) មិនត្រូវបានគោរពឡើយ ដោយហេតុថា មិនមានការផ្តល់សំអាងហេតុចំពោះការផ្តន្ទាទោសលើរូបគាត់។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសន្និដ្ឋានថា សិទ្ធិរបស់គាត់ត្រូវបានរំលោភបំពាន ដោយបានបញ្ជាក់ថា ៖

> យោងតាមយុត្តិសាស្ត្ររបស់ខ្លួន សាលក្រម ឬសាលដីការបស់តុលាការ ឬសាលាក្តីទាំងឡាយ ត្រូវផ្តល់សំអាងហេតុឱ្យបានសមរម្យ ដែលសាលក្រម ឬសាលដីកានោះយកមកធ្វើជាមូលដ្ឋាន...។ យោងតាមយុត្តិសាស្ត្ររបស់ខ្លួន តុលាការបានសម្រេចជាញឹកញយថា សំអាងហេតុនៅក្នុងសេចក្តីសម្រេចរបស់តុលាការត្រូវតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងផលប្រយោជន៍នៃការធានាដល់ការជំនុំជម្រះដោយយុត្តិធម៌ ដែលធ្វើដូច្នេះ វានឹងការពារសិទ្ធិរបស់ចុងចោទ។ សំអាងហេតុនេះមានប្រយោជន៍ដល់តម្លៃនៃយុត្តិធម៌ ហើយផ្តល់ជាយន្តការក្នុងការការពារប្រឆាំងនឹងការចេញសេចក្តីសម្រេចតាមទំនើងចិត្ត។

តុលាការនេះបានកត់សម្គាល់ទៀតថា ដោយសារតែសេចក្តីសម្រេចពុំមានសំអាងហេតុពេញលេញគ្រប់គ្រាន់ "តុលាការកំពូលមិនអាចពិនិត្យលើបណ្តឹងឧទ្ធរណ៍ដោយប្រសិទ្ធភាព ហើយជាឧទាហរណ៍ មិនអាចកំណត់ចំណុចខ្វះខាត ឬចំណុចមិនស៊ីសង្វាក់ទាំងឡាយនៅក្នុងសំអាងហេតុបានឡើយ"។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D353/2/3 កថាខណ្ឌ ២៤-២៦, ការពិភាក្សា និងការដកស្រង់រឿងក្តី Taxquet ទល់នឹង បែលហ្ស៊ិក Eur. Ct. H.R. ពាក្យសុំលេខ 926/05 (2009)។

[៦១] ដូចខាងលើ កំណត់សម្គាល់ ៣៤ ដកស្រង់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីអត្ថាធិប្បាយ ទូទៅលេខ ៣២៖ មាត្រា ១៣៖ សិទ្ធិទទួលបាននូវសមភាពនៅចំពោះមុខតុលាការ និងសាលាក្តីនានា និងទទួលបាននូវការ ជំនុំជម្រះដោយយុត្តិធម៌ កថាខណ្ឌ ៤៩ ឯកសារអង្គការសហប្រជាជាតិ *CCPR/C/GC/32* (ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧) និងរឿងក្តី *Smith ទល់នឹង ប្រទេសហ្សាម៉ែកា* ទស្សនៈរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ កថាខណ្ឌ 10.5 ឯកសារអង្គការសហប្រជាជាតិ។

**បណ្តឹងសាទុក្ខរបស់លោកអៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់លោកអៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធ**

នោះ គួរតែផ្អែកទៅលើមូលដ្ឋានអ្វី និងដើម្បីឱ្យអង្គបុរេជំនុំជម្រះមានលទ្ធភាពសម្រេចថា តើ សហចៅក្រមស៊ើបអង្កេតមានកំហុសដែរឬទេ[៦២]។

តាមពិត នៅក្នុងសេចក្តីសម្រេចផ្សេងមួយទៀត អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា "សេចក្តីសម្រេច *ទាំងអស់* របស់តុលាការតម្រូវឱ្យផ្តល់សំអាងហេតុ ដោយសារវាជាបទដ្ឋានអន្តរជាតិ"[៦៣]។

៣៩. យុត្តិសាស្ត្រនៃសាលាក្តី *មិនអចិន្ត្រៃយ៍* ទាំងឡាយ ក៏គាំទ្រសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុដែរ[64]។ ឧទាហរណ៍ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Prlić *និងជនដទៃទៀត*

---

[៦២] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ D353/2/3 កថាខណ្ឌ ២៤-២៨ (សម្រង់ កថាខណ្ឌ ២៨)។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសម្រេចដែលមានសំអាងហេតុមិនគ្រប់គ្រាន់បែបនេះ មិនអាចឱ្យអង្គបុរេជំនុំជម្រះអនុវត្តភារកិច្ចរបស់ខ្លួន ក្នុងការពិនិត្យឱ្យមានប្រសិទ្ធិភាព ទៅលើសេចក្តីសម្រេចនោះ ហើយរារាំងអង្គបុរេជំនុំជម្រះមិនឱ្យកំណត់បានអំពីថាតើ សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវដែរឬទេ។ ដូចខាងលើ កថាខណ្ឌ ២៩។

[៦៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ឯកសារលេខ D55/I/8 កថាខណ្ឌ ២១ (សេចក្តីបញ្ជាក់បន្ថែម)។

[64] *សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង* Prlić *និងជនផ្សេងទៀត* IT-04-74-AR73.13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ Jadranko Prlić ដែលបានប្តឹងរួមលើដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៦ និង ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការទទួលយកភស្តុតាង ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ កថាខណ្ឌ ១៨៖ "អង្គជំនុំជម្រះតុលាការកំពូលសូមរំលឹកថា អង្គជំនុំជម្រះសាលាដំបូងត្រូវផ្តល់សំអាងហេតុ ដើម្បីផ្តល់ជាមូលដ្ឋានលើការរកឃើញរបស់ខ្លួនលើសេចក្តីពិចារណាសំខាន់ៗពាក់ព័ន្ធនឹងសេចក្តីសម្រេច"។ *រដ្ឋអាជ្ញា ទល់នឹង* Prlić *និងជនផ្សេងទៀត* IT-04-74-AR73.4 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានសម្រេចបន្ថយរយៈពេលសម្រាប់រឿងក្តីរបស់រដ្ឋអាជ្ញា ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌ ១៦៖ "អង្គជំនុំជម្រះតុលាការកំពូលសូមរំលឹកថា អង្គជំនុំជម្រះសាលាដំបូង យ៉ាងហោចណាស់ ត្រូវផ្តល់សំអាងហេតុ ក្នុងកម្រិតអប្បបរមា ដើម្បីផ្តល់ជាមូលដ្ឋានលើការរកឃើញរបស់ខ្លួនលើសេចក្តីពិចារណាសំខាន់ៗពាក់ព័ន្ធនឹងសេចក្តីសម្រេច..."។ *រដ្ឋអាជ្ញា ទល់នឹង* Haradinaj *និងជនផ្សេងទៀត* IT-04-84-AR65.2 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ Lahi Braimaj ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើសុំដោះលែងបណ្តោះអាសន្ន ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ១០៖ " យ៉ាងហោចណាស់ [អង្គជំនុំជម្រះ] ត្រូវផ្តល់សំអាងហេតុ ក្នុងកម្រិតអប្បបរមា ដើម្បីផ្តល់ជាមូលដ្ឋានលើការរកឃើញរបស់ខ្លួនលើសេចក្តីពិចារណាសំខាន់ៗ

អង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយបណ្ដឹងសាទុក្ខមួយរបស់រដ្ឋអាជ្ញា ដែលបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងខកខានពុំបានផ្ដល់សំអាងហេតុឱ្យបានគ្រប់គ្រាន់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ដោយបានបន្ថយរយៈពេលសម្រាប់រដ្ឋអាជ្ញានៅក្នុងការបង្ហាញរឿងក្ដី។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា "អង្គជំនុំជម្រះសាលាដំបូងត្រូវផ្ដល់សំអាងហេតុដើម្បីជាមូលដ្ឋានគាំទ្រដល់ការយល់ឃើញរបស់ខ្លួនអំពីសំខាន់ៗពាក់ព័ន្ធនឹងសេចក្ដីសម្រេច"។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្ដល់សេចក្ដីសម្រេចដែលមានសំអាងហេតុ វាជាការគ្រប់គ្រាន់ដែល "ថាអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញឯកសារ និងព័ត៌មាន ដែលខ្លួនបានពិចារណា ព្រមទាំកត្តាផ្សេងៗ ដែលខ្លួនបានយកមកពិចារណានៅពេលវាយតម្លៃចំណុចនៅសល់ដែលត្រូវលើកឡើងចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែ ដោយត្រូវបញ្ជាក់បានច្បាស់លាស់នៅក្នុងការវាយតម្លៃនោះថា នៅពេលខ្លួនបំពេញកាតព្វកិច្ចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានថ្លឹងថ្លែងយ៉ាងត្រឹមត្រូវលើផលប្រយោជន៍ដែលមានការប្រទាំងប្រទិសគ្នា ដើម្បីធានាឱ្យមានយុត្តិធម៌ និងភាពឆាប់រហ័សនៃដំណើរការនីតិវិធី"[65]។

---

ពាក់ព័ន្ធនឹងសេចក្ដីសម្រេច"។ *រដ្ឋអាជ្ញា ទល់នឹង Nyiramasuhuko និងជនផ្សេងទៀត* ICTR-98-42-AR73 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ Joseph Kanyabashi ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៧ ស្ដីពីការច្រានចោលពាក្យសុំកែប្រែបញ្ជីសាក្សី ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ ១៨០។ *រដ្ឋអាជ្ញា ទល់នឹង Sesay និងជនផ្សេងទៀត* SCSL-04-15-A សាលដីកា ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៤៤៖ "លក្ខខណ្ឌនៃការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងលក្ខន្តិកៈរួមបញ្ចូលទាំងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានមតិយោបល់ដែលមានសំអាងហេតុដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមមាត្រា ១៨ នៃលក្ខន្តិកៈ និងវិធាន ៨៨(គ)នៃវិធាន។ អង្គជំនុំជម្រះតុលាការកំពូលរកឃើញយុត្តិសាស្ត្រដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវនៅតុលាការ ICTY និងតុលាការ ICTR ដែលបកស្រាយបទប្បញ្ញត្តិដូចៗគ្នារបស់ខ្លួន ថាមានលក្ខណៈគួរឱ្យជឿជាក់ដូចច្បាប់ផងដែរ នៅក្នុងន័យនេះ"។

[65] *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនផ្សេងទៀត* IT-04-74-AR73.4 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់រដ្ឋអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការរក្សាការឃុំខ្លួន និងការបញ្ជាក់បន្ថែម ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ កថាខណ្ឌ ២៥។

៤០. សេចក្ដីសម្រេចដែលត្រូវបានជំទាស់មានសំអាងហេតុមិនគ្រប់គ្រាន់។ សេចក្ដីសម្រេចនេះខកខានមិនបានពន្យល់ពីហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលសំណើសុំឱ្យបង្គាប់ដល់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន ឱ្យធ្វើប្រាស្រ័យទាក់ទងដោយចំហ និងដោយតម្លាភាពជាមួយនឹងភាគីនានា។ សំអាងហេតុតែមួយគត់នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់នេះគឺពាក់ព័ន្ធនឹងករណីថាតើភាគីទាំងឡាយអាច ដឹកនាំការសួរសំណួរលើសាក្សីតែប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់សំអាងហេតុថា ដោយហេតុថាការបែងចែកការទទួលខុសត្រូវលើការតាំងសំណួរ គឺជាសេចក្ដីសម្រេចដែលផ្អែកលើឆន្ទានុសិទ្ធិ ហើយពុំបើកឱ្យមានការផ្ដល់ទឡ្ហីករណ៍តទល់គ្នានោះ "ដូច្នេះ វាជាការសមរម្យដែល ការធ្វើទំនាក់ទំនងគ្នានេះគឺត្រូវធ្វើឡើងចំពោះភាគីដែលពាក់ព័ន្ធតែប៉ុណ្ណោះ"[66]។

៤១. អង្គជំនុំជម្រះសាលាដំបូងពុំអើពើនឹងការរំលោភលើសិទ្ធិទាំងឡាយដែលបានកើតឡើងនៅគ្រប់ពេលដែលមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនផ្ដល់ព័ត៌មានទៅដល់ភាគីមួយចំនួន ប៉ុន្តែមិនបានផ្ដល់ព័ត៌មានទាំងនេះជូនទៅភាគីផ្សេងទៀត ហើយពុំបានពន្យល់ហេតុផលដែលខ្លួនយល់ឃើញថា ការធ្វើដូច្នេះត្រូវបានអនុញ្ញាតឡើយ។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលខកខានពុំបានចេញសេចក្ដីសម្រេចដែលមានសំអាងហេតុ ដោយហេតុថាវាជាលក្ខខណ្ឌតម្រូវឱ្យចេញសេចក្ដីសម្រេចដែលមានសំអាងហេតុ។ នៅពេលពុំបានចេញសេចក្ដីសម្រេចដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើឱ្យប៉ះពាល់ដោយចេតនាលើសិទ្ធិរបស់ភាគីក្នុងការធ្វើបណ្ដឹងសាទុក្ខ ដោយអង្គជំនុំជម្រះសាលាដំបូងពុំបានផ្ដល់សំអាងហេតុតាមផ្លូវច្បាប់ ក្នុងកម្រិតមួយជាក់លាក់ ក្នុងការអនុញ្ញាតិឱ្យធ្វើការប្រាស្រ័យទាក់ទងបែបនេះ ហើយនៅក្នុងករណីនេះ បានលើកទឹកចិត្តនិងបង្គាប់ឱ្យប្រាស្រ័យទាក់ទង*តែជាមួយភាគីម្ខាង* ដែលច្បាប់ពុំអនុញ្ញាតឱ្យធ្វើបែបនេះទេ។ កំហុសបែបនេះនាំឱ្យមោឃភាពដល់សេចក្ដីសម្រេច ហើយបង្កើតជាការជ្រៀតជ្រែកនៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដោយហេតុថាវាបណ្ដាលឱ្យមានការរំលោភលើសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី ពោលគឺសិទ្ធិទទួលបានតម្លាភាពនៃកិច្ចដំណើរការនីតិវិធី ហើយវាជាការរំលោភលើសិទ្ធិរបស់លោក ក្នុងការទទួលបានការពិនិត្យឡើងវិញចំពោះបណ្ដឹងសាទុករបស់គាត់។

---

[66] ដីកាសម្រេចដែលត្រូវបានជំទាស់ ទំព័រ ១។

## V. សេចក្តីសន្និដ្ឋាន និងសំណើសុំ

៤២. តាមរយៈការចេញសេចក្តីសម្រេចដែលពុំមានសំអាងហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានព្យាយាមពង្រឹងដំណើរការពុំមានតម្លាភាព ដោយអង្គជំនុំជម្រះសាលាដំបូង តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់ដែលពុំមានការទទួលខុសត្រូវរបស់ខ្លួន បានធ្វើឲ្យស្របច្បាប់ការប្រព្រឹត្តមិនដោយមិនស្មើភាពគ្នាចំពោះភាគីផ្សេងៗ តាមរយៈការប្រើប្រាស់ការប្រាស្រ័យទាក់ទង*តែជាមួយភាគីម្ខាង* លើបញ្ហាសំខាន់ៗ ដែលផ្ទុយនឹងពាក្យពេជន៍ និងស្មារតីនៃច្បាប់គ្រប់គ្រង អ.វ.ត.ក ដែលឃើញមានមូលដ្ឋាន និងគាំទ្រដោយវដ្តធម្មនុញ្ញផងដែរ។ ការលើកឡើងថាការប្រាស្រ័យទាក់ទង*ជាមួយតែភាគីម្ខាង* គឺជាការចាំបាច់ និងជាការសមហេតុផលនៅក្នុងការដោះស្រាយទៅនឹងបញ្ហានានា ដែលប៉ះពាល់ដោយផ្ទាល់ និងដោយជាក់លាក់លើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ ឬ របស់ភាគីណាមួយផ្សេងទៀតនោះ គឺជាការលើកឡើងដោយមិនបានពិចារណាទាល់តែសោះ ប្រសិនបើមិនមែនគួរឲ្យស្អប់ខ្ពើមខ្លាំងទេ។ ក្នុងនាមជាតុលាការគំរូមួយ[67] ការអនុវត្តដែលគេគិតទុកថានឹងចម្លងតាមតុលាការកម្ពុជាទាំងអស់ និងជាកេរតំណែលដ៏យូរ

---

[67] "អ.វ.ត.ក បានបង្កើតឡើងជាតុលាការគម្រូមួយសម្រាប់ការកែទម្រង់ប្រព័ន្ធតុលាការ និងប្រព័ន្ធច្បាប់។ ហេតុដូច្នេះ អ.វ.ត.ក មិនគួរធ្វើជាតុលាការគម្រូចំពោះការដាក់កំហិតដោយពុំចាំបាច់លើការបញ្ចេញមតិដោយសេរី និងការទទួលបានព័ត៌មាននោះឡើយ"។ អនុសាសន៍ពាក់ព័ន្ធនឹងតម្លាភាពបន្ថែមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដែលដាក់ជូនដោយសមាជិកសង្គមស៊ីវិល និងសមាជិកសារព័ត៌មានកម្ពុជា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ អាចរកបានតាមរយៈគេហទំព័រ http://www.cambodiatribunal.org/CTM/Recommendations%20Regarding%20Additional%20Transparency.pdf?phpMyAdmin=8319ad34ce0db941ff04d8c788f6365e។ *សូមមើលផងដែរ* Holly Telerant & Pen Rany, ***Must Justice be Seen to be Done? Public Scrutiny and Participation in the KRT***, VOICE OF JUSTICE RESEARCH BULLETIN ឆ្នាំទី ១៤ លេខ ១៣៦ ខែ មីនា - មេសា ឆ្នាំ ២០០៧ ទំព័រ ១៥-១៨ (គូសបញ្ជាក់បន្ថែម)។ "សាលាក្តីខ្មែរក្រហមបានបង្កើតឡើងសម្រាប់ប្រជាពលរដ្ឋកម្ពុជា ទៅតាមហេតុផលដែលបានពិចារណាយ៉ាងហ្មត់ចត់ជាច្រើន។ សាលាក្តីនេះមិនត្រឹមតែបានបង្កើតឡើងដើម្បីនាំចារីយកមកធ្វើការជំនុំជម្រះប៉ុណ្ណោះទេ មិនតែប៉ុណ្ណោះ សាលាក្តីនេះបានបង្កើតឡើងដើម្បីស្វែងរកយុត្តិធម៌ផងដែរ។ សាលាក្តីនេះបានបង្កើតឡើងដើម្បីបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រឲ្យបានត្រឹមត្រូវ ដើម្បីជម្រុញការពិភាក្សាក្នុងថ្នាក់ជាតិ និងដើម្បីចាប់ផ្តើមដំណើរការផ្សះផ្សាជាតិដែលបានអូសបន្លាយជាយូរមកហើយ។

អង្វែងនោះ[68] អង្គជំនុំជម្រះសាលាដំបូង ហើយប្រសិនបើពុំមានការកែតម្រូវបញ្ហានេះទេ នោះអង្គជំនុំជម្រះតុលាការកំពូល នឹងធ្វើឱ្យនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជាកាន់តែចុះខ្សោយ ដែលដូចស្ថានភាពនីតិរដ្ឋនៅកម្ពុជា

---

វាមានការពិបាកក្នុងការទទួលបានគោលបំណងទាំងនេះ ប្រសិនបើដំណើរការមុនការជំនុំជម្រះសំខាន់ៗនានា បានធ្វើឡើងជាលក្ខណៈឯកជនសុទ្ធសាធនោះ"។

[68] ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សបានចេញរបាយការណ៍មួយ ដែលកំណត់ "កេរតំណែល"នៅក្នុងបរិបទតុលាការទាំងឡាយ ដូចជា អ.វ.ត.ក ថានឹង "មានអានុភាពឋិតថេរជារៀងរហូតលើការជម្រុញនីតិរដ្ឋនៅក្នុងសង្គមមួយជាក់លាក់ តាមរយៈការជំនុំជម្រះដោយមានប្រសិទ្ធភាព ដើម្បីចូលរួមចំណែកបញ្ចប់និទណ្ឌភាព ហើយក្នុងពេលជាមួយគ្នានេះដែរ ពង្រឹងសមត្ថភាពប្រព័ន្ធតុលាការនៅក្នុងស្រុក។ គោលបំណងនេះ គឺដើម្បីបន្តនិរន្តភាព ទោះបីបក្រោយពីតុលាការចម្រុះនេះបានបញ្ចប់ក៏ដោយ។ ភាពចាំបាច់ក្នុងការបន្សល់កេរតំណែលនេះ បានទទួលស្គាល់យ៉ាងរឹងមាំថាជាផ្នែកមួយនៃគោលនយោបាយរបស់អង្គការសហប្រជាជាតិ" *Rule-of-Law Tools for Post-Conflict States: Maximizing the Legacy of Hybrid Courts* ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស ឆ្នាំ ២00៨ ទំព័រ ៤៥ អាចរកបានតាមរយៈគេហទំព័រ http://www.ohchr.org/Documents/Publications/HybridCourts.pdf។ របាយការណ៍នេះលើកឡើង វិធីដែលអយ្យការធ្វើការងារលើការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្ស គឺមានសារៈសំខាន់ដូចនឹងអ្វីដែលអយ្យការបានធ្វើនេះដែរ។ *ដូចខាងលើ* ទំព័រ ៥។ គេកត់សម្គាល់ឃើញថា៖

> [អ្វី]ដែលសំខាន់គឺថា តុលាការចម្រុះនេះទំនងជាត្រូវបានគេតាមដានយ៉ាងហ្មត់ចត់ និងត្រូវគោរពឱ្យបានខ្ជាប់ខ្ជួនលើគោលការណ៍ខ្ពស់ៗបំផុតៗនៅក្នុងការអនុវត្តរបស់ខ្លួនលើគ្រប់វិស័យ ដើម្បីពង្រីកឱ្យដល់កម្រិតអតិបរមានៃផលប៉ះពាល់ដែលបានបង្ហាញឱ្យឃើញ។ និយាយដោយខ្លី ទាំងនេះគឺជាឧទហរណ៍៖
>
> - *បទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌* វិធីសាស្ត្រដ៏រឹងមាំមួយចំពោះបញ្ហានៃការជំនុំជម្រះដោយយុត្តិធម៌ និងសមភាពរវាងគូភាគីក្តី ជាសំខាន់នឹងនាំឱ្យមានការទទួលស្គាល់តួនាទីដ៏សំខាន់របស់ក្រុមមេធាវីការពារក្តី។ ដោយហេតុថាការផ្លាស់ប្តូរវប្បធម៌មួយ នឹងទាមទារឱ្យផ្តល់ធនធានឱ្យបានសមរម្យដល់ក្រុមមេធាវីការពារក្តី ដូច្នេះ ជាឧទាហរណ៍ វានឹងអាចបណ្តាលឱ្យជំនួយផ្លូវច្បាប់កាន់តែប្រសើរឡើងសម្រាប់ជនជាប់ចោទក្រីក្រនៅក្នុងតុលាការក្នុងស្រុក។
>
> [...]

បច្ចុប្បន្នដែលមិនមានភាពទៀងទាត់ តាមរយៈការជម្រុញ និងលើកទឹកចិត្តឱ្យមានការអនុវត្ត ដែលផ្ទុយនឹងគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ និងមានតម្លាភាព ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ អង្គជំនុំជម្រះសាលាដំបូងពុំគួររំលោភដោយគ្មានហេតុផលទៅលើសិទ្ធិរបស់ភាគី តាមរយៈការប្រើប្រាស់ការប្រាស្រ័យទាក់ទង*ជាមួយតែភាគីម្ខាង* ដោយពុំបានផ្តល់ឱកាសឱ្យភាគីដាក់សារណារបស់ខ្លួន និងធ្វើឱ្យមានជាកំណត់ហេតុតុលាការឱ្យបានត្រឹមត្រូវ ដោយបានចេញសេចក្តីសម្រេចតាមរយៈអនុស្សរណៈដែលពុំមានសំអាងហេតុ និងដោយចូលរួមក្នុងការប្រព្រឹត្តិ ដែល ទោះដោយចេតនាក្តី ឬ ដោយអចេតនាក្តី បានគេចវេសមិនគោរពទៅតាមលក្ខខណ្ឌធានានៅក្នុងប្រព័ន្ធតុលាការកម្ពុជា ដែលធានាយុត្តិធម៌ និងការជំនុំជម្រះដោយត្រឹមត្រូវ ដែលលក្ខខណ្ឌធានានេះគឺជាអ្វីដែលចៅក្រមបានធ្វើសច្ចាប្រណិធានថានឹងគោរពឱ្យបានខ្ជាប់ខ្ជួននៅពេលបំពេញមុខងាររបស់ខ្លួន។

ហេតុដូចបានលើកឡើងនៅក្នុងហេតុផលខាងលើ ក្រុមមេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល៖

ក. សម្រេចទទួលយកបណ្តឹងសាទុក្ខនេះ។

ខ. អនុញ្ញាតឱ្យមានសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈលើបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ។

---

- *តម្លាភាពនៃស្ថាប័នសាធារណៈ និងកម្រិតនៃវិជ្ជាជីវៈ* ដើម្បីទទួលជោគជ័យ <u>ស្ថាប័នចម្រុះ</u>ត្រូវធ្វើយ៉ាងណាឱ្យគេយល់ថាជាស្ថាប័នមួយតម្លាភាព និងអាចឱ្យគេធ្វើទំនាក់ទំនងបាន។ ការធ្វើទំនាក់ទំនងជាមួយនឹងមន្ត្រីជាន់ខ្ពស់របស់តុលាការ និងការទទួលបានព័ត៌មានច្បាស់លាស់ នឹងផ្តល់អានុភាពជាវិជ្ជមានលើរបៀបដែលគេមើលឃើញចំពោះតុលាការ ដែលវាជាការកំណត់នូវសេចក្តីរំពឹងទុកជាក់ស្តែងលើអ្វីដែលតុលាការអាចសម្រេចបាន។ ការចាត់ចែងហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវក៏ជាចំណុចពិចារណាដ៏មានសារៈសំខាន់ មិនខុសពីបទដ្ឋាននៃក្រមវិជ្ជាជីវៈ និងក្រមសីលធម៌ផងដែរ។

*ដូចខាងលើ* ទំព័រ ១៧ - ១៨ (គូសបញ្ជាក់បន្ថែម)។

គ. សម្រេចថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការណែនាំឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនចូលរួមនៅក្នុងការប្រាស្រ័យទាក់ទង*ជាមួយតែភាគីម្ខាង* នៅក្នុងការបង្គាប់កុំឱ្យភាគីឆ្លើយតបទៅនឹងសំណើសុំ និងនៅក្នុងការខកខានពុំបានចេញសេចក្ដីសម្រេចដែលមានសំអាងហេតុ។

ឃ. ចាត់ទុកសេចក្ដីសម្រេចដែលត្រូវបានជំទាស់នេះជាមោឃៈ និង

ង. បង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ឈប់ និងកុំបង្គាប់ដល់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនធ្វើការប្រាស្រ័យទាក់ទង*ជាមួយតែភាគីម្ខាង* លើបញ្ហាទាំងឡាយណាដែលប៉ះពាល់ ឬ ដែលជាប់ពាក់ព័ន្ធនឹងកិច្ចដំណើរការជំនុំជម្រះលើសំណុំរឿង ០០២។

សូមអង្គជំនុំជម្រះទទួលយកបណ្ដឹងសាទុក្ខ និងសំណើរបស់យើងខ្ញុំដោយក្ដីគោរព។

________________ ____________________

**អាង ឧត្តម** Michael G. KARNAVAS

**សហមេធាវីការពារក្ដីលោក អៀង សារី**

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១១។